ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការគ្រប់គ្រង និងការពារជម្ងឺញ៉ូកាស




រៀបចំដោយ **នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម**

សហការជាមួយ **នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល**



ឧបត្ថម្ភដោយ **គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី**

**រៀបរៀងដោយៈ បណ្ឌិតរង សន សាន**

**ប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាល**

**នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល**

ទូរស័ព្ទៈ ០១២ ៩៣៩៦២៩

អ៊ីម៉ែលៈ sorn.san@online.com.kh

**កាលបរិច្ឆេទៈ ខែ វិច្ឆិកា ឆ្នាំ ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

**បុព្វកថា**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID)តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធ កេ្សត្រ-បរិស្ថាន ថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗ ទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មានបច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយក ទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទគាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាលភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ (បទដ្ឋានអនុវត្តបច្ចេកវិទ្យា)។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យាដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្រ្តីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និង ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្រ្តីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៍ កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់។ បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអបត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប មាននៅតាមស្ថាប័ននានាដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័តនិងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន ។

# ការគ្រប់គ្រង និងការពារជម្ងឺញ៉ូកាស


១. សេចក្តីផ្តើម ........................................ ១

២. ការពិពណ៌នា ........................................ ១

៣. ការណែនាំបច្ចេកទេស ........................................ ២

៣.១ ការបង្ហាញ បអប " TIP " ........................................ ២

ក. ជម្ងឺញ៉ូកាស........................................ ៤

១. តើអ្វីទៅជាជម្ងឺញ៉ូកាស? ........................................ ៤

២. រោគសញ្ញានៃជម្ងឺញ៉ូកាស ........................................ ៤

*២-១. ជម្ងឺនេះស្រដៀងគ្នានឹងជម្ងឺដទៃផ្សេងទៀត ........................................ ៦*

*២-២. តើអ្នកដឹងប្រាកដដោយរបៀបណាថាជាជម្ងឺញ៉ូកាស? ........................................ ៧*

*២.៣ តើបក្សីឆ្លងជម្ងឺនេះតាមរយៈណាខ្លះ? ........................................៩*

៣.ស្ថានភាពជម្ងឺញ៉ូកាសនៅកម្ពុជា ........................................ **Error! Bookmark not defined.**

ខ. តើអ្វីជាការត្រួតពិនិត្យជម្ងឺ?........................................១០

១. វិធានការត្រួតពិនិត្យជម្ងឺញ៉ូកាសនៅកម្ពុជា: ........................................១០

*១-១. ការចាក់វ៉ាក់សាំង ........................................១០*

*១.១.១. ការចាក់វ៉ាក់សាំងរំលឹ*

*........................................**Error! Bookmark not defined.***

*១.១.២.*

*ការថែទាំវ៉ាក់សាំង........................................**Error! Bookmark not defined.***

*១.១.៣.*

*វ៉ាក់សាំងបន្តក់តាមភ្នែក........................................**Error! Bookmark not defined.***

*១.១.៤*

*តើត្រូវធ្វើដូចម្តេចដើម្បីលាយវ៉ាក់សាំងធ្វើការបន្តក់ភ្នែកឱ្យបានត្រឹមត្រូវ?........................................១៣*

*១.១.៥.*

*វ៉ាក់សាំងសំរាប់ផឹក........................................**Error! Bookmark not defined.***

*១.១.៦.*

*វ៉ាក់សាំងជម្ងឺញ៉ូកាសដែលបានប្រើប្រាស់នៅកម្ពុជារួចហើយ........................................**Error! Bookmark not defined.***

*១.១.៧.*

*វ៉ាក់សាំងជម្ងឺញ៉ូកាសដែលបានប្រើប្រាស់បច្ចុប្បន្ននៅតំបន់ភាគច្រើនរបស់កម្ពុជា........................................**Error! Bookmark not defined.***

*១.១.៨. រដូវកាលនៃការចាក់វ៉ាក់សាំងប្រឆាំងនឹងជម្ងឺញ៉ូកាស........................................ **Error! Bookmark not defined.***

២. ការត្រួតពិនិត្យចលនាសត្វបក្សី ........................................១៧

៣. វិធានការត្រួតពិនិត្យនៅពេលផ្ទុះជម្ងឺ ........................ ១៩

*៣.១- ការឃ្លាំមើល* ........................ ១៩

៤. ការអនុវត្តជីវសុវត្ថិភាពឱ្យកាន់តែប្រសើរ........................ ១៩

៥. ការរាយការណ៍........................ ២៥

៦. អប់រំអ្នកភូមិពីជម្ងឺញ៉ូកាស (ការអប់រំសាធារណជន) ........................ ២៧

គ. តួនាទីភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយភូមិក្នុងការត្រួតពិនិត្យ ជម្ងឺញ៉ូកាស ........................ ៣២

ឃ. តើភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវធ្វើអ្វីខ្លះ? ........................ ៣៤

១. ការអង្កេតឃ្លាំមើល ........................ ៣៤

២. ការត្រួតពិនិត្យ និងរាយការណ៍ ........................ ៣៥

៣. ការបញ្ឈប់ជម្ងឺ ........................ [illegible]

ង. និន្នភាពគេងនៃផលិតកម្មមាន់តាមភូមិ និងវិធានការការពារជម្ងឺញ៉ូកាស........................ ៣៦

ច. ជម្ងឺផ្តាសាយបក្សី ........................៣៩

១. រោគសញ្ញាចំពោះបក្សី ........................៤០

## ១. សេចក្តីផ្តើម

ការចិញ្ចឹមបក្សីជាលក្ខណៈឱ្យដើររកស៊ីដោយសេរីគឺជាប្រភពប្រូតេអ៊ីនដ៏សំខាន់និងផ្តល់ប្រាក់ចំណូលបន្ថែមដល់គ្រួសារកសិករនៅតាមជនបទកម្ពុជា ។

គ្រួសារកសិករប្រមាណ ៩០ ទៅ៩៥ភាគរយចិញ្ចឹមមាន់ ហើយវាដើរនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ កសិករក្រីក្រអាចចិញ្ចឹមបក្សីបាន ដោយសារវាចំណាយដើមទុនតិច និងចិញ្ចឹមក្នុងរយៈពេលខ្លី ។ បច្ចុប្បន្ននេះ អត្រាងាប់មាន់ក្នុងឆ្នាំដំបូងបន្ទាប់ពីញាស់រួចមានអត្រា ៨០ ទៅ៩០ភាគរយ ។

ជម្ងឺញ៉ូកាស គឺជាជម្ងឺមួយក្នុងចំណោមជម្ងឺដែលមានអត្រាស្លាប់ខ្ពស់លើមាន់នៅប្រទេសកម្ពុជា និងធ្វើឱ្យខាតបង់យ៉ាងធ្ងន់ធ្ងរ បណ្តាលឱ្យកសិករជាច្រើនរួញរាក្នុងការចិញ្ចឹមមាន់នេះ ។ វ៉ាក់សាំងរបស់វាមានលក្ខណៈងាយស្រួលក្នុងការដឹកជញ្ជូន និងការចាក់វ៉ាក់សាំង ទោះបីជាចំនួនភាគរយនៃកសិករនាពេលបច្ចុប្បន្នមានចំនួនតិចដែលចាក់វ៉ាក់សាំងឱ្យមាន់ក៏ដោយ ។ ភ្នាក់ងារសុខភាពសត្វភូមិ មានវត្តមានស្ទើរតែគ្រប់ភូមិ និងទទួលបានការបណ្តុះបណ្តាលពីការដឹកជញ្ជូន និងចាក់វ៉ាក់សាំង ។

## ២. ការពិពណ៌នា

| | |
|---|---|
| ឈ្មោះ | : ការគ្រប់គ្រងជម្ងឺញ៉ូកាស |
| ថ្ងៃ ខែ ឆ្នាំ | : ខែ កុម្ភៈឆ្នាំ២០០៦ |
| ប្រភព TIP | : លោក ស៊ិន សាន ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវផលិតកម្ម និងបសុព្យាបាលនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ។ |
| គោលបំណង និងផលប្រយោជន៍ | គោលបំណងសំខាន់នៃ បអប សំរាប់ការគ្រប់គ្រងជម្ងឺញ៉ូកាសមានដូចខាងក្រោម |

- ជួយភ្នាក់ងារផ្សព្វផ្សាយ ភ្នាក់ងារសុខភាពសត្វភូមិក្នុងការត្រួតពិនិត្យជម្ងឺញ៉ូកាសកាន់តែប្រសើរ ក្នុងគោលបំណងបង្កើនផលិតកម្មមាន់ ឆ្ពោះទៅរកការបង្កើនសុវត្ថិភាពស្បៀងអាហារ និងចំណូលគ្រួសារ ។
- ដើម្បីផ្តល់បច្ចេកទេស និងណែនាំផ្សព្វផ្សាយដល់ភ្នាក់ងារផ្សព្វផ្សាយ ភ្នាក់ងារសុខភាពសត្វភូមិ ។
- ដើម្បីកាត់បន្ថយ អត្រាស្លាប់របស់បក្សីដែលបណ្តាលមកពីជម្ងឺញ៉ូកាស និងបង្កើនផលិតកម្មមាន់ ។

- ដើម្បីផ្តល់វិធានជីវសុវត្ថិភាពកាន់តែប្រសើរ ដើម្បីការពារជម្ងឺញ៉ូកាសនៅតាមភូមិ។
- លើកទឹកចិត្តកសិករ ដើម្បីឱ្យធ្វើការចាក់វ៉ាក់សាំងបក្សីរបស់ពួកគាត់។
- បង្កើនការយល់ដឹងពីជម្ងឺ ដំណើរការវិវត្តន៍ជម្ងឺ និងការអនុវត្តការទប់ស្កាត់ជម្ងឺជាទូទៅ។

## ៣. ការណែនាំបច្ចេកទេស

### ៣.១ ការបង្ហាញ បអប " *TIP* "

នៅប្រទេសកម្ពុជា ការចិញ្ចឹមមាន់តាមភូមិមានស្ទើរគ្រប់ផ្ទះ នេះបើតាមការធ្វើជំរឿននៅខែវិច្ឆិកា ២០០៤ ដែលបង្ហាញថាមានបក្សី (មាន់ ទា) ជាង៩០% ចិញ្ចឹមតាមគ្រួសារ។ កសិករចិញ្ចឹមមាន់ តាមគ្រួសារមានប្រហែលជា ២លាន។ ការចិញ្ចឹមមាន់នៅតាមភូមិ ជួយបំពេញការខ្វះខាតបានច្រើនផ្នែក ដូចជា មាន់ទាំងនោះផ្តល់សាច់ និងស៊ុតធ្វើជាអាហារសំរាប់ពិធីបុណ្យសំខាន់ៗ និងបុណ្យប្រពៃណីផ្សេងៗទៀត វាថែមទាំងជួយក្នុងការកំចាត់សត្វល្អិត និងផ្តល់ប្រាក់កាសនៅពេលដែលការចំណាយតិចតួចលើ កំលាំងពលកម្ម និងការថែទាំមានតិចតួចប៉ុណ្ណោះ ហើយការចិញ្ចឹមតាមលក្ខណៈគ្រួសារនេះ វាប៉ះពាល់ បរិស្ថានតិចតួច។ ឧបសគ្គចំបង សំរាប់ការចិញ្ចឹមមាន់ តាមភូមិនៅប្រទេសកម្ពុជា គឺជម្ងឺញ៉ូកាស។ ជម្ងឺនេះ គឺជាមូលហេតុ សំខាន់នៃការស្លាប់បក្សី។ ផ្តាសាយបក្សី ដែលពីមុនគេស្គាល់ថា ជាអាសន្នរោគនោះ គឺជាជម្ងឺ មានលក្ខណៈស្រដៀងនឹងជម្ងឺញ៉ូកាសដែរ។វាគឺជម្ងឺមួយកាចសាហាវកើតលើបក្សីតាំងពីឆ្នាំ១៨៧៨ មកម្ល៉េះ។ នៅខែ មករា ឆ្នាំ២០០៤ ផ្តាសាយបក្សីបានកើតដំបូងនៅព្រះរាជាណាចក្រកម្ពុជា ហើយបានក្លាយជាជម្ងឺដ៏សាហាវ ដែលបំផ្លាញមាន់ គ្រួច និងទា។

ការទប់ស្កាត់ជម្ងឺញ៉ូកាស ត្រូវបានធ្វើរួចហើយនៅតាមតំបន់មួយចំនួននៅព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពទាំងនេះ ត្រូវបានរៀបចំចាត់ចែងឡើងដោយភ្នាក់ងារសុខភាពសត្វភូមិ ភ្នាក់ងារផ្សព្វផ្សាយ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន។ ការទប់ស្កាត់ជាទូទៅ គឺពឹងផ្អែកលើការចាក់វ៉ាក់សាំងលើបក្សីទាំងតូច និងធំជាមួយវ៉ាក់សាំង I-2 ដែលនាំចូលពីវៀតណាម។

TIP នេះផ្តោតជាសំខាន់ទៅលើការការពារ និងទប់ស្កាត់ជម្ងឺញ៉ូកាសនៅតាមភូមិដោយៈ

- ផ្តល់ចំណេះដឹង ទៅការអនុវត្តបច្ចេកទេសល្អៗ សំរាប់ការការពារ និងទប់ស្កាត់ជម្ងឺញ៉ូកាស
- កែលំអរការអនុវត្តវិធានជីវសុវត្ថិភាពនៅតាមគ្រួសារចិញ្ចឹមមាន់ (រួមមានការពង្រឹងការប៉ះពាល់រវាងបក្សីស្រុក និងបក្សីព្រៃ រវាងជ្រូក និងបក្សីស្រុក)
- ចាក់វ៉ាក់សាំងលើបក្សីទាំងអស់ជាទៀងទាត់ចន្លោះ ៤ខែម្តង។
- កែលំអរការធ្វើចលនាសត្វបក្សី

- លើកទឹកចិត្តកសិករឱ្យអនុវត្តការហូបអាហារដែលមានសុវត្ថិភាពដោយមិនត្រូវហូបមាន់ឈឺ ឬងាប់
- មិនត្រូវលក់មាន់ឈឺ ឬមាន់ដែលបានប៉ះពាល់ជាមួយបក្សីឈឺ ឬងាប់

បអប នេះត្រូវបានរៀបរៀងឡើងសំរាប់ភ្នាក់ងារសុខភាពសត្វភូមិ ភ្នាក់ងារផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតបង្កើនចំណេះដឹងមូលដ្ឋាន និងបច្ចេកទេស ដើម្បីជួយកសិករការពារ និងទប់ស្កាត់ជម្ងឺញ៉ូកាសនៅតាមភូមិក្នុងការកាត់បន្ថយអត្រាងាប់និងបង្កើនផលិតកម្មបក្សីនៅតាមភូមិព្រមទាំងរួម ចំណែកកាត់បន្ថយភាពក្រីក្រចំពោះកសិករផងដែរ។

រួមគ្នាភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយ,កសិករនឹងត្រូវលើកទឹកចិត្តដើម្បីឱ្យពួកគេយកមាន់របស់ពួកគេមកចាក់វ៉ាក់សាំង និងឱ្យពួកគេកែលំអរការអនុវត្តវិធានជីវសុវត្ថិភាពក្នុងការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសាររបស់ពួកគេ។ បអប នេះ នឹងផ្តល់ផងដែរនូវចំណេះដឹងដ៏គួរឱ្យទុកចិត្តសំរាប់កសិករក្នុងការអនុវត្តវិធានល្អសំរាប់ការពារ និងទប់ស្កាត់ជម្ងឺញ៉ូកាសនៅតាមភូមិ។

បអបនេះត្រូវបានរៀបរៀងឡើងសំរាប់បណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិនិងភ្នាក់ងារផ្សព្វផ្សាយក្នុងប្រទេសកម្ពុជាពីជម្ងឺញ៉ូកាស។

បអប នេះ គឺផ្តោតសំខាន់ទៅលើវិធានការការពារ និងទប់ស្កាត់ជម្ងឺញ៉ូកាស

បអប នេះត្រូវបានរៀបរៀងដើម្បីបណ្តុះបណ្តាលអំពីៈ

- តើត្រូវអង្កេតឃ្លាំមើល និង ទប់ស្កាត់ជម្ងឺញ៉ូកាសនៅតាមភូមិយ៉ាងដូចម្តេច?
- តើត្រូវបញ្ឈប់ជម្ងឺញ៉ូកាសយ៉ាងដូចម្តេច?
- តើត្រូវធ្វើរបាយការណ៍ និងកត់ត្រាសត្វបក្សីមាន់ ទា និងបក្សីដទៃទៀតងាប់ បញ្ជូនទៅពេទ្យសត្វស្រុក និងមជ្ឈមណ្ឌលជាតិស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាលយ៉ាងដូចម្តេច?
- តើត្រូវផ្តល់ព័ត៌មាន និងបញ្ចុះបញ្ចូលអ្នកភូមិពីជម្ងឺញ៉ូកាសដោយរបៀបណា?

# ក- ជម្ងឺញ៉ូកាស

## ១- តើអ្វីទៅជាជម្ងឺញ៉ូកាស?

ជម្ងឺញ៉ូកាស (ND) បណ្តាលមកពីប៉ារ៉ាមីកូវីរុស (Paramyxovirus) ដែលប៉ះពាល់តែលើពួកបក្សី ហើយមាន់គឺជាសត្វដែលងាយទទួលជម្ងឺជាងគេ។ នៅពេលដែលអត្រាស្លាប់មានកំរិតខ្ពស់ សត្វដទៃទៀតដូចជាមាន់ជាំងជុង (Turkeys) ព្រាបក៏ត្រូវរងនូវការឆ្លងរាលដាលដែរ។ ជាទូទៅទាធន់នឹងជម្ងឺញ៉ូកាសក៏ប៉ុន្តែមានករណីខ្លះកូនទាអាចកើតជម្ងឺនេះ។

នៅប្រទេសកម្ពុជា ជម្ងឺញ៉ូកាសធ្វើឱ្យមាន់នៅតាមភូមិ និងនៅតាមកសិដ្ឋានស្លាប់ក្នុងអត្រាខ្ពស់។ ជម្ងឺញ៉ូកាសនេះត្រូវបានគេហៅឈ្មោះក្នុងស្រុកជាច្រើនដូចជាដង្កោកាច់ និងតែវៃកាច់។

### តើអ្វីទៅជាវីរុស?

- ☞ វីរុសគឺជាមេរោគមានទំហំតូចបំផុត ដែលមិនអាចមើលឃើញតាមរយៈមីក្រូទស្សន៍ធម្មតា។ វីរុសអាចបំបែកខ្លួនក្នុងកោសិកាសត្វ មនុស្ស ហើយសម្លាប់កោសិកាដែលវារស់នៅ។ វាបង្កឱ្យសត្វ និងមនុស្ស ឆ្លងជម្ងឺ និងឈឺ។
- ☞ វីរុសអាចមើលឃើញតែតាមរយៈមីក្រូទស្សន៍សំរាប់មើលវីរុស ដែលមានការកត់ត្រារបៀបរស់រវើងរបស់វា។

## ២- រោគសញ្ញានៃជម្ងឺញ៉ូកាស

រោគសញ្ញានៃជម្ងឺញ៉ូកាសមានការប្រែប្រួលអាស្រ័យទៅតាមកំរិត និងការរស់នៅរបស់វីរុស:

- ជាមួយនិងស្រ្តេនវីរុសញ៉ូកាសដែលមានកំលាំងខ្លាំង មាន់អាចងាប់ដោយមិនបានបង្ហាញនូវរោគសញ្ញា។

- មាន់ត្រសុសរោមវា ហើយបង្ហាញនូវលក្ខណៈ (ត្រដាងស្លាបនៅលើដី)។

- មាន់មានលក្ខណៈអស់កំលាំង និង មិនស៊ីចំណី។

- សញ្ញាប្រព័ន្ធដង្ហើមដូចជាសូរក្រឹត១ និងឮសូរដូចគេកាត់អ្វី អាចត្រូវសំគាល់បើពិនិត្យសង្កេតអោយបានជិតដល់។

- សញ្ញាប្រព័ន្ធប្រសាទដូចជាញាក់សាច់ ថ្លោះសរសៃក (Torticollis) ប៉ារ៉ាលីស៊ីសស្លាប និងជើងត្រូវបានសំគាល់ឃើញតែក្នុងករណីជម្ងឺស្ថិតក្នុងកំរិតខ្លាំងក្លា។

 

<u>កសិករនៅភាគផ្សេងៗនៃពិភពលោក សំគាល់ឃើញថា</u>

<u>មាន់ដែលមានជម្ងឺញ៉ូកាសតែងមានសញ្ញាសញ្ញា (ត្រដាងស្លាបនៅលើដី)</u>

 

ការថ្លោះសរសៃក ជាទូទៅសង្កេតឃើញចំពោះមាន់កើតជម្ងឺញ៉ូកាស

តែក្នុងករណីជម្ងឺស្ថិតនៅដំណាក់កាលខ្លាំងក្លា

- រមួលក និង ជើង
- លាមកមានពណ៌ខៀវ
- ផលិតកម្មស៊ុតចំពោះមាន់ ពងមានការថយចុះយ៉ាងខ្លាំង ។ ជួនកាលស៊ុតដែលចេញមកខូចទំរង់ និងទ្រង់ទ្រាយ ។

 

- ភាគរយនៃការស្លាប់មាន់មានកំរិតខ្ពស់ ជួនកាលឡើងរហូតដល់ ៦០- ១០០ ភាគរយ ។

 

នៅពេលដែលអត្រាងាប់ត្រូវបានសង្កេតឃើញក្នុងហ្វូងមាន់ដែលមានពី ៦០ ទៅ ១០០ ភាគរយ ភាគច្រើន ជម្ងឺញូកាសគឺជាភ្នាក់ងារបង្កហេតុ ។

**សូមកុំធ្វើការវះកាត់ពិនិត្យសាកសពមាន់ និងបក្សីដទៃទៀតឱ្យសោះ** ពីព្រោះវាអាចគ្រោះថ្នាក់ដល់សុខភាពរបស់អ្នក ហើយនឹងត្រូវការចាំបាច់នូវសំភារៈបរិក្ខារពិសេស។ វាមានគ្រោះថ្នាក់ណាស់ ពីព្រោះនៅពេលមាន់ និងបក្សីដទៃទៀតឆ្លងជម្ងឺហើយ វីរុសស្ថិតនៅក្នុងសាច់ ឆ្អឹង លាមក ។ល។ និងអាចឆ្លងទៅភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយដែលអនុវត្តការវះកាត់ពីព្រោះយើងមិនដឹងថាវាកើតជម្ងឺអ្វីនោះទេ តើជម្ងឺញូកាស ឬផ្តាសាយបក្សី។

## ២-១. ជម្ងឺនេះស្រដៀងគ្នានឹងជម្ងឺដទៃផ្សេងទៀត

មានជម្ងឺដទៃទៀតដែលអាចសម្លាប់មាន់ ហើយអាច ច្រឡំជាមួយនិងជម្ងឺញូកាស ឧទាហរណ៍ដូចជាៈ **ជម្ងឺផ្តាសាយបក្សី** និង **ជម្ងឺប៉េស្តទាចំពោះសត្វទា** គឺបង្កឡើងដោយសារវីរុស (គ្មានថ្នាំព្យាបាលទេ)។ មាន់តែងតែងាប់ ហើយវាពិបាកនឹងដឹងថាវាកើតជម្ងឺអ្វីនោះទេ តើវាជាជម្ងឺញូកាស ឬផ្តាសាយបក្សី គឺមានតែលទ្ធផលនៅមន្ទីរពិសោធន៍ទេដែលអាចបញ្ជាក់ពិតប្រាកដ។

**ជម្ងឺអាសន្នរោគបក្សី (Fowl Cholera)** មានលក្ខណៈស្រដៀងគ្នាដែរ ប៉ុន្តែវាបង្កឡើងដោយសារបាក់តេរី។ អ្នកអាចបញ្ឈប់ការងាប់បាន ប្រសិនបើអ្នកចាក់បញ្ចូលថ្នាំអង់ទីប៊ីយ៉ូទិចក្នុងកំរិតមួយគ្រប់គ្រាន់។

**ជម្ងឺរលាកទងសួត (Infectious bronchitis)**

**ជម្ងឺហ្គុមបូរូ (Gumboro)**

**ជម្ងឺផ្តាសាយ (Infectious Coryza)**

**ជម្ងឺរាគឈាម (Coccidiosis)**

**ការពុល** ជារឿយៗ អ្នកភូមិចោលសារធាតុគីមីទៅលើវាលស្រែជុំវិញផ្ទះ ឬក្នុងស្រះទឹក។ សារធាតុគីមីនេះអាចសំលាប់មាន់ជាច្រើនក្បាល។ វាជាប្រការល្អមួយក្នុងការជំរុញឱ្យអ្នកភូមិសំអាត បរិវេណជុំវិញផ្ទះឱ្យបានត្រឹមត្រូវ (កប់ ដុតកាកសំណល់ ) និងការពារស្រះ។

## ២-២. តើអ្នកដឹងច្បាស់ដោយរបៀបណាថាជាជម្ងឺញ៉ូកាស?

នៅពេលការងាប់មានលក្ខណៈគួរឱ្យសង្ស័យមែននោះ អ្នកត្រូវហៅពេទ្យសត្វស្រុក។ គាត់នឹងធ្វើការប្រមូលវត្ថុវិភាគឬសាកសពនឹងបញ្ជូនវាទៅមន្ទីរពិសោធន៍របស់មជ្ឈមណ្ឌលជាតិស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាលនៅទីក្រុងភ្នំពេញឱ្យបានឆាប់បំផុតក្នុងលក្ខណៈប្រកបដោយសុវត្ថិភាព។ ពួកគេនឹងធ្វើការវិភាគហើយ១ ឬ២ថ្ងៃក្រោយមកពួកគេនឹងដឹងថាតើវាជាជម្ងឺញ៉ូកាស ឬក៏មិនមែន។ ពួកគេត្រូវតែផ្តល់ព័ត៌មានស្តីពីលទ្ធផលឱ្យអ្នកបានដឹង។

**មានតែលទ្ធផលមន្ទីរពិសោធន៍ទេ ដែលបញ្ជាក់ច្បាស់ថា វាជាជម្ងឺញ៉ូកាសឬក៏មិនមែន។**

**ជម្ងឺញ៉ូកាសគឺជាជម្ងឺបង្កគ្រោះមហន្តរាយពីព្រោះ**

+ ជម្ងឺនេះអាចសម្លាប់មាន់ និងបក្សីដទៃទៀតចំនួន ៦០ ទៅ ១០០% នៅក្នុងភូមិ ។
+ ជម្ងឺនេះមានលក្ខណៈឆ្លងរាលដាលខ្លាំងណាស់ អាចឆ្លងពីភូមិមួយទៅភូមិមួយផ្សេងទៀតពីស្រុកមួយទៅស្រុកមួយផ្សេងទៀតក្នុងប្រទេសទាំងមូល។
+ ប្រសិនបើមិនបានទប់ស្កាត់ឱ្យបានលឿនទាន់ពេលវេលានោះទេ ជម្ងឺនេះនឹងបន្តឆ្លងរាលដាលយ៉ាងឆាប់រហ័សនៅក្នុងភូមិ ហើយជារៀងរាល់ឆ្នាំយើងនឹងជួបបញ្ហានេះដដែលៗ

**អង់ទីប៊ីយ៉ូទិចគ្មានប្រសិទ្ធិភាព ក្នុងការព្យាបាលជម្ងឺញ៉ូកាសទេ។**

**មេរោគញ៉ូកាសឆ្លងរាលដាលឆាប់រហ័សណាស់ (អាចរាលដាលដល់ហ្វូងដែលនៅជិតខាង) និងយើងអាចរកឃើញមេរោគនេះ នៅគ្រប់ការបញ្ចេញចោលមកខាងក្រៅពីបក្សី បានឆ្លងជម្ងឺជាពិសេសក្នុងលាមក សត្វ ការបញ្ចេញពីទឹកមាត់ និងសំបោរ។**

**ប្រសិនបើមាន់ និងបក្សីដទៃទៀតរបស់អ្នកបានប៉ះពាល់ជាមួយមាន់ និងបក្សីដទៃទៀតមានជម្ងឺ។ ពួកវានឹងចាប់ផ្តើមឈឺ ២ ទៅ៣ថ្ងៃបន្ទាប់។**





<u>ការពិនិត្យរកមេរោគជម្ងឺញ៉ូកាសនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាល</u>

## អត្រាសត្វងាប់

**ជាអកុសល** អ្នកភូមិតែងតែជួបប្រទះនឹងបញ្ហាមាន់ និងបក្សីដទៃទៀតងាប់ជារៀងរាល់ឆ្នាំ (ភាគច្រើនក្នុងខែមេសាររដូវបុណ្យចូលឆ្នាំខ្មែរ យោងតាមរបាយការណ៍សម្ភាសន៍ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយចំនួន៦ខេត្ត)។ វាជារឿងសំខាន់ណាស់ក្នុងការចំណាំ នូវអត្រាសត្វងាប់ដ៏គួរឱ្យ សង្ស័យទាំងនោះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានដើម្បីបញ្ឈប់ការឆ្លងរាលដាលជម្ងឺនេះភ្លាមៗ។

**អត្រាសត្វងាប់** មានន័យថា ចំនួនមាន់ និងបក្សីដទៃទៀតកំពុងងាប់។

### មាន់ជាច្រើនងាប់

- យើងពិបាកនឹងនិយាយថា មានមាន់ជាច្រើនក្បាលងាប់ នៅពេលណាគ្រួសារ នោះមានមាន់តែ ២ ឬ ៣ ឬ ៥ ក្បាលនោះ ។
- ប៉ុន្តែវាជាក់ស្តែងណាស់ថាមានមាន់ ៤ក្បាលងាប់ក្នុងចំណោមមាន់៥ក្បាល នោះគឺយើងអាចនិយាយបានថាមានមាន់ជាច្រើនងាប់។
- វាជារឿងងាយស្រួលចំណាំប្រសិនបើម្ចាស់មានមាន់ ២០ ទៅ៣០ក្បាល។ ប្រសិនបើមានមាន់ ១៥ ទៅ ១៦ក្បាលងាប់ នោះមានន័យថាមានមាន់ងាប់ច្រើន ។ ប្រសិនបើមានមាន់ ១ ឬ ២ ងាប់ នោះបានន័យថាមិនទាន់មានមាន់ងាប់ច្រើនឡើយទេ ប៉ុន្តែត្រូវពិនិត្យមើលនៅថ្ងៃបន្តបន្ទាប់ទៀត។

### មាន់ងាប់ក្នុងរយៈពេលតិចជាងមួយថ្ងៃ

✲ មានកសិករជាច្រើនបាននិយាយថា កាលពីល្ងាចមាន់មាន សុខភាពល្អហើយវាឡើង ដើមឈើ ប៉ុន្តែនៅពេលព្រឹកគាត់ ឃើញមានមាន់ខ្លះងាប់នៅលើដី។ នេះគឺជាប្រការមួយគួរឱ្យ សង្ស័យយ៉ាងជាក់ស្តែង។

### មាន់ងាប់បន្ថែមទៀតជារៀងរាល់ថ្ងៃ

✲ ប្រសិនបើអ្នកដឹងថាមានផ្ទះមួយមានមាន់១ ឬ២ងាប់ នោះវាមិនធ្ងន់ធ្ងរណាស់ណានោះទេ។ ប៉ុន្តែអ្នកត្រូវទៅកន្លែងនោះជារៀងរាល់ថ្ងៃ ក្នុងរយៈពេល ៤ឬ៥ថ្ងៃជាប់ៗគ្នា។ អ្នកនឹងកត់សម្គាល់ថាតើមានមាន់ច្រើនថែមទៀតងាប់ដែរឬទេ។ ប្រសិនបើអ្នកឃើញថា ជារៀងរាល់ថ្ងៃ មានមាន់ងាប់ច្រើនឡើងៗនោះ គឺជាប្រការគួរឱ្យសង្ស័យហើយ។

### ការងាប់កំពុងតែឆ្លងរាលដាល



✲ ផ្ទះដែលនៅជិតខាងប្រឈមមុខនឹងការងាប់ក្នុងថ្ងៃបន្ទាប់មក។ នៅពេលអ្នកចុះទៅមើលកន្លែងមួយដែលមានមាន់ងាប់ ជារៀងរាល់ថ្ងៃក្នុងរយៈពេល ៤ ឬ៥ថ្ងៃជាប់ៗគ្នា អ្នកត្រូវទៅមើលផ្ទះដែលនៅជិតខាងនោះដែរ ពីព្រោះមាន់វាដើរជុំវិញនោះ និងទៅប៉ះពាល់ជាមួយនឹងមាន់គេចិញ្ចឹមនៅផ្ទះក្បែរគ្នា។ ប្រសិនបើមាន

មាន់ងាប់ក្នុងផ្ទះជាច្រើន នោះគឺជាប្រការគួរឱ្យសង្ស័យ ។

### ២.៣ តើបក្សីឆ្លងជម្ងឺនេះតាមរយៈណាខ្លះ?

**នៅប្រទេសកម្ពុជាយើង របៀបចម្លងជម្ងឺផ្តាសាយបក្សីមានដូចតទៅៈ**

- ការចិញ្ចឹមហ្វូងទា ព្រលែងដោយសេរី
- ការចិញ្ចឹមមាន់លែងជាលក្ខណៈគ្រួសារ
- ការចិញ្ចឹមសត្វមាន់ និងបក្សីដទៃទៀតជាលក្ខណៈគ្រួសារ ខ្វះជីវសុវត្ថិភាព
- ចលនាមាន់ និងបក្សីដទៃទៀត
- ការជល់មាន់
- ការប៉ះពាល់ជាមួយនឹងលាមក (វីរុសអាចរស់នៅក្នុងលាមករយៈពេលយូរ) ។

### ៣-ស្ថានភាពជម្ងឺផ្តាសាយបក្សីនៅកម្ពុជា

- ការរាតត្បាតជម្ងឺនេះ ច្រើនកើតមាននៅរវាងពិធីបុណ្យចូលឆ្នាំខ្មែរ ។ តម្លៃវ៉ាក់សាំងប្រែប្រួលទៅតាមបណ្តាខេត្ត នានា ។ មានសម្ភារៈតិចតួចសម្រាប់ផ្សព្វផ្សាយជម្ងឺនេះ ហើយមានកសិករច្រើនណាស់ ដែលមិនយល់ពីការចាក់វ៉ាក់សាំងប្រឆាំងនឹងជម្ងឺផ្តាសាយនេះ ។
- ជម្ងឺផ្តាសាយជាជម្ងឺមួយ ដែលធ្វើឱ្យមាន់យ៉ាងច្រើននៅតាមភូមិងាប់ យោងតាមការសម្ភាសន៍ជាមួយកសិករចំនួន ៦ខេត្ត ។
- កសិករតែងតែចង់សន្សំលុយ ហើយហូប និងលក់មាន់ឈឺ ។ វាមានគ្រោះថ្នាក់ណាស់ និងធ្វើឱ្យមានការឆ្លងមេរោគទៅភូមិផ្សេងៗទៀត ។

**<u>9 ត្រូវចងចាំ</u>**

- ផ្តាសាយជាជម្ងឺឆ្លងដែលបង្កដោយវីរុស និងឆ្លងរាលដាលយ៉ាងឆាប់រហ័ស ។ ជម្ងឺនេះបង្កឱ្យមាន់ និងបក្សីដទៃទៀតងាប់យ៉ាងច្រើនក្បាល ។
- ផ្តាសាយជាជម្ងឺបង្កមហន្តរាយ ។ អង់ទីប៊ីយ៉ូទិច មិនអាចព្យាបាលជម្ងឺនេះបានទេ ។
- ប្រសិនបើមាន់ និងបក្សីដទៃទៀតរបស់អ្នកបានប៉ះពាល់ជាមួយមាន់ និងបក្សីដទៃទៀតមានជម្ងឺ ។ ពួកវានឹងចាប់ផ្តើមឈឺ ២ ទៅ៣ថ្ងៃបន្ទាប់ ។
- អ្នកត្រូវស្ថិតក្នុងភាពប្រុងប្រយត្ន័ខ្ពស់នៅពេលឃើញមាន់ និងបក្សីដទៃទៀតកំពុងងាប់ ។

## ២. តើអ្វីជាការត្រួតពិនិត្យជម្ងឺ?

ការត្រួតពិនិត្យជម្ងឺមានន័យថាជាសកម្មភាពមួយដែលមានបំណងការពារទប់ស្កាត់ ដើម្បីកាត់បន្ថយជម្ងឺ ឬធ្វើឱ្យជាសះស្បើយឡើងវិញ។

### ១- វិធានការត្រួតពិនិត្យជម្ងឺញ៉ូកាសនៅកម្ពុជា

ការចាក់វ៉ាក់សាំងញ៉ូកាសអាចកាត់បន្ថយអត្រាស្លាប់មាន់យ៉ាងច្រើននៅតាមភូមិ។ ទោះបីជាយ៉ាងនេះក៏ដោយ ការចាក់វ៉ាក់សាំងត្រូវតែរួមផ្សំជាមួយវិធានការផ្សេងៗទៀត ដូចជាការត្រួតពិនិត្យចលនាសត្វ ការឃ្លាំមើល ការអនុវត្តជីវសុវត្ថិភាពឱ្យកាន់តែប្រសើរការរាយការណ៍ និងការអប់រំសាធារណជនគឺ វិធានការយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ។

### ១-១. ការចាក់វ៉ាក់សាំង

មានវ៉ាក់សាំងជាច្រើនប្រភេទ ឧទាហរណ៍ដូចជា La Sota, Muteswar និង I2។ វ៉ាក់សាំងប្រភេទនីមួយៗត្រូវបានគេប្រើប្រាស់តាមបែបផ្សេងៗគ្នា ដូច្នេះត្រូវច្បាស់ថាតើវ៉ាក់សាំងត្រូវប្រើប្រាស់បែបណាចំពោះបក្សី។ ជាមួយនឹង I2 អ្នកអាចរក្សាទុកវាក្នុងរយៈពេលបាន ២ថ្ងៃបន្ទាប់ពីបើកគំរបវាប្រើប្រាស់ ប៉ុន្តែវ៉ាក់សាំងដទៃទៀត មិនអាចប្រើប្រាស់ក្រៅតែពីថ្ងៃដែលយើងបើកគំរបទេ។

មាន់គួរទទួលចាក់វ៉ាក់សាំងយ៉ាងហោចណាស់មួយខែ មុនជម្ងឺផ្ទុះឡើង។ ជាការប្រសើរត្រូវសួរទៅអ្នកចិញ្ចឹមមាន់ តើនៅពេលណាដែលជាទូទៅជម្ងឺផ្ទុះឡើង ហើយធ្វើផែនការចាក់វ៉ាក់សាំងមុនពេលដែលជម្ងឺផ្ទុះឡើង។ អ្នកគួរតែចាក់វ៉ាក់សាំងទៅលើមាន់ដែលមានសុខភាពល្អ។ មាន់ និងស៊ុតវាដែលបានចាក់វ៉ាក់សាំងរួចម្តងអាចយកទៅបរិភោគដោយគ្មានបញ្ហា។



<u>ការចាក់វ៉ាក់សាំងញ៉ូកាសនៅតាមភូមិ</u>

- ការចាក់វ៉ាក់សាំងរលឹក

ប្រសិទ្ធិភាពនៃវ៉ាក់សាំង នឹងថយចុះប្រសិនបើយើងមិនចាក់វារំលឹកទេនោះ។ ចំនួននៃការចាក់រំលឹកវា **អាស្រ័យទៅនឹងរបៀបដែលត្រូវផ្តល់វ៉ាក់សាំងទៅបក្សីៈ**

**វ៉ាក់សាំងបន្តក់ៈ** ចាក់រំលឹករៀងរាល់ ៤ខែម្តង

**វ៉ាក់សាំងសំរាប់ផឹកៈ** ចាក់រំលឹករៀងរាល់ ៣ខែម្តង

**វ៉ាក់សាំងលាយជាមួយចំណីៈ** ចាក់រំលឹករៀងរាល់ ២-៣ខែម្តង

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវតែប្រាប់កសិករថា វ៉ាក់សាំងធ្វើឡើងពីវីរុសដែលមិនអាចសម្លាប់មាន់ទេ ប៉ុន្តែវាដូចនឹងវីរុសដែលបំផ្លាញសត្វមាន់។

មាន់ត្រូវការពេលវេលាដើម្បីទទួលភាពសាុំពីវ៉ាក់សាំង។ ពេលវេលាលើកក្រោយដែលមាន់ជួបប្រទះជាមួយ នឹងមេរោគញ៉ូកាសវានឹងបញ្ចេញប្រតិកម្មទប់ទល់យ៉ាងឆាប់រហ័សដើម្បីទប់ទល់មេរោគដែលបង្កជំងឺញ៉ូកាស។ ទោះបីជាយ៉ាងណាក៏ដោយ ប្រពន្ធ័ទប់ទល់នេះនឹងថយចុះដោយសារពេលវេលា ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការចាក់រំលឹកឱ្យមាន់។

ការថែទាំវ៉ាក់សាំង

ក-ការថែរក្សា និងការដឹកជញ្ជូនវ៉ាក់សាំង

វាមានសារៈសំខាន់ណាស់ ក្នុងការពន្យល់អំពីការប្រើប្រាស់ និងការថែរក្សាវ៉ាក់សាំងនៅពេលកំពុងបើក និងបន្ទាប់ពីបើកគំរបរួច នៅក្រៅធុងទឹកកក។

- ❈ វ៉ាក់សាំងញ៉ូកាសអាចរក្សានៅខាងក្រៅធុងទឹកកកម្តងម្កាល ប៉ុន្តែវាមិនត្រូវដាក់ឱ្យប៉ះនឹងពន្លឺព្រះអាទិត្យ និងមិនត្រូវដាក់កន្លែងក្តៅ។
- ❈ មិនត្រូវទុកវ៉ាក់សាំងនៅកន្លែងត្រជាក់ខ្លាំង ឬកន្លែងសំរាប់ធ្វើឱ្យទឹកក្លាយជាទឹកកក
- ❈ ត្រូវថែរក្សាវ៉ាក់សាំងនៅកន្លែងដែលមានសីតុណ្ហភាពថេរ។ វ៉ាក់សាំងទាំងនេះ នឹងថយប្រសិទ្ធិភាពនៅពេលដែលសីតុណ្ហភាពផ្លាស់ប្តូរ។ នៅពេលដែលអ្នកថែរក្សាក្នុងទូរទឹកកកមិនត្រូវដាក់វា នៅជាប់នៅទ្វារឡើយ ព្រោះវានឹងផ្លាស់ប្តូរសីតុណ្ហភាពរៀងរាល់ពេលទូរទឹកកកត្រូវគេបើក។
- ❈ ប្រសិនបើវ៉ាក់សាំង ត្រូវបានគេរក្សាបានត្រឹមត្រូវនៅចន្លោះសីតុណ្ហភាព ៤ ទៅ៨ អង្សារសេ នោះវានឹងមានប្រសិទ្ធិភាពប្រើប្រាស់រហូតដល់ថ្ងៃផុតកំនត់នៃការប្រើប្រាស់ ។ វ៉ាក់សាំងនឹងមិនអាចមានប្រសិទ្ធិភាពប្រើប្រាស់រហូតដល់ថ្ងៃផុតកំនត់នៃការប្រើប្រាស់ ប្រសិនបើយើងផ្លាស់ប្តូរ សីតុណ្ហភាពនៅក្នុងទូរទឹកកក។
- ❈ នៅពេលដកចេញពីធុងទឹកកក វ៉ាក់សាំងញ៉ូកាសដែលមិនបិទជិតអាចប្រើប្រាស់បាន មួយរយៈពេលទៀត ប្រសិនបើរក្សាវាទុកក្នុងកន្លែងត្រជាក់ (សីតុណ្ហភាព ២២អង្សាសេ ឬតិច ជាងនេះ) កន្លែងងងឹត។ នៅតាមភូមិត្រូវដាក់ដបវ៉ាក់សាំងកន្លែងដែលស្អាតក្បែរក្អមដាក់ទឹកធ្វើពីដីឥដ្ឋកន្លែងងងឹត។

វ៉ាក់សាំងត្រូវរក្សាឱ្យឆ្ងាយពីដៃរបស់កុមារ។ ប្រសិនបើវ៉ាក់សាំងញ៉ូកាសដែលមិនបិទជិតដាក់ឱ្យត្រូវក្តៅក្នុងសីតុណ្ហភាព ៣២អង្សារសេ វាអាចប្រើប្រាស់បានមួយ រយៈពេល ២-៣ថ្ងៃ ទៀតប៉ុណ្ណោះ។

- ❋ កាលណាគេបើកគំរបដបរបស់វ៉ាក់សាំង វាអាចបន្តប្រើប្រាស់យូរ ប្រសិនបើវារក្សាទុកក្នុងសីតុណ្ហភាព ប្រមាណ ២២ អង្សារសេ ប៉ុន្តែយកល្អត្រូវប្រើប្រាស់វាឱ្យកាន់តែឆាប់កាន់តែល្អ។
- ❋ រយៈពេលនៃការប្រើប្រាស់វ៉ាក់សាំងញ៉ូកាសដែលគេដាក់នៅខាងក្នុងឬខាងក្រៅធុងទឹកកកប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយទៀតអាស្រ័យទៅតាមវិធីសាស្ត្រនៃការប្រើប្រាស់ និងការដឹកជញ្ជូនវ៉ាក់សាំង។ ខិត្តបណ្ណ័ដែលផ្តល់ជាមួយនឹងវ៉ាក់សាំងដែលយើងទិញ នឹងផ្តល់ការណែនាំពីពេលវេលាថែរក្សាទុកវ៉ាក់សាំង និងរបៀបប្រើប្រាស់។

ជានិច្ចកាលដឹកជញ្ជូនវ៉ាក់សាំងនៅទីវាលដោយប្រើប្រាស់ប្រអប់ទឹកកក ឬកញ្ចប់ទឹកកក ប្រសិនបើមាន។ ប្រសិនបើគ្មានប្រអប់ទឹកកក ឬកញ្ចប់ទឹកកកទេ ខ្ចប់ដបវ៉ាក់សាំងជាមួយក្រណាត់ ហើយដាក់វាក្នុងកន្ត្រកត្បាញដែលចំហ ឬដាក់ធុង ឬប្រអប់អាចឱ្យខ្យល់ចេញចូលបានក្នុងគោលបំណងថែរក្សាវ៉ាក់ សាំងឱ្យត្រជាក់ និងមិនឱ្យត្រូវពន្លឺព្រះអាទិត្យ។

ខ-ការថែរក្សាវ៉ាក់សាំងដទៃទៀត

វ៉ាក់សាំងប្រភេទដទៃទៀត ដូចជា La Sota និង Muteswar ត្រូវរក្សាទុកនៅសីតុណ្ហភាពថេរក្នុងចន្លោះរវាង ៤ ទៅ ៨អង្សាសេនៅទូរទឹកកក ឬក៏ប្រអប់ត្រជាក់ដាក់ទឹកកក។

**វ៉ាក់សាំងបន្តក់តាមភ្នែក**

ការបន្តក់តាមភ្នែក គឺវាមានប្រសិទ្ធិភាពណាស់ក្នុងការធ្វើវ៉ាក់សាំងឱ្យបក្សីប្រឆាំងនឹងញ៉ូកាស។ វ៉ាក់សាំង I2 ឬ La Sota ត្រូវបានលាយជាមួយទឹកស្អាត (គ្មានសារធាតុក្លរ) និងត្រូវបានចាក់ទៅឱ្យមាន់តាមអាយុរបស់វា។ ដើម្បីបន្តក់អោយបានត្រឹមត្រូវយើងត្រូវធ្វើការសាកល្បងវា ដើម្បីបញ្ជាក់ថា ១តំណក់គឺ១កំរិត។ តំណក់ថ្នាំរបស់វ៉ាក់សាំងត្រូវបន្តក់ឱ្យស្មើដែលល្អទៅក្នុងភ្នែករបស់បក្សី។ បុគ្គលិកបសុពេទ្យភ្នាក់ងារផ្សព្វផ្សាយ និងកសិករខ្លួនឯងត្រូវតែហាត់ធ្វើការបន្តក់វ៉ាក់សាំងឱ្យបានត្រឹមត្រូវ។




តើត្រូវធ្វើដូចម្ដេចដើម្បីលាយវ៉ាក់សាំងធ្វើការបន្តក់ភ្នែកឱ្យត្រឹមត្រូវ?

ចំនួនទឹកលាយជាមួយនឹងវ៉ាក់សាំងស្ងួតឱ្យបានត្រឹមត្រូវ គឺយោងទៅតាមទំហំនៃតំណក់ថ្នាំនៃប្រដាប់បន្តក់ ឬសីរ៉ាំង និងចំនួនកំរិតនៅក្នុងដបវ៉ាក់សាំង។ ជាការប្រសើរត្រូវប្រើប្រដាប់បន្តក់ដែលមានកំរិត ៤0ដំណក់ក្នុង ១មីលីលីត្រ។

ត្រូវធ្វើការត្រួតពិនិត្យទៅលើប្រដាប់បន្តក់ ឬសីរ៉ាំង ដើម្បីឱ្យប្រាកដថាមាន់ទទួលបានវ៉ាក់សាំងត្រឹមត្រូវតាមកំរិត។

វិធីសាស្ត្រដែលរៀបរាប់ខាងក្រោម គឺជាគំនិតមួយសំរាប់អ្នកមិនសូវយល់ដឹងពីការគណនាក្នុងការលាយវ៉ាក់សាំង។ ប្រសិនបើធ្វើការគណនាការលាយវ៉ាក់សាំងរួមគ្នាឱ្យបានគ្នាពីរនាក់វាជាការប្រសើរ។

១- ត្រូវពិនិត្យចំនួនកំរិតវ៉ាក់សាំងនៅលើដប

២- បើកគំរបប្រដាប់បន្តក់ (រូបភាពទី១, ជំហានទី១) ចាក់បំពេញទឹកទៅលើប្រដាប់បន្តក់

៣- ( ជំហានទី២) និងបិទគំរបវិញ ( ជំហានទី៣)

៤- ដកឆ្នុកស៊ីរ៉ាំង ១0 ម.ល ចេញ ( ជំហានទី៤) និងកាន់ស៊ីរ៉ាំងបញ្ឈរមុខចុះក្រោម ។ ត្រូវយក មេដៃខ្ទប់ចុងសីរ៉ាំង ( ជំហានទី៥)

៥- កាន់បញ្ឈរប្រដាប់បន្តក់ក្បាលចុះមកក្រោម ហើយច្របាច់ថ្នមៗ និងរាប់ចំនួនតំណក់ដែលធ្លាក់ចូលក្នុងសីរ៉ាំង ( ជំហានទី៦)។ បន្តរាប់ចំនួនតំណក់ រហូតដល់ចំនួនតំណក់ស្មើនឹងចំនួនកំរិតវ៉ាក់សាំងដែលមាននៅក្នុងដប។ ដើម្បីងាយស្រួលក្នុងការរាប់តំណក់ទឹកលាយ យើងរាប់ ១0តំណក់ម្ដង។ ឧទាហរណ៍ប្រសិនបើវ៉ាក់សាំងមាន ១00 កំរិត យើងគួររាប់ ១0 ដង។ ត្រូវរាប់ដោយមានគ្នា ២នាក់ ម្នាក់រាប់ ម្នាក់ទៀតកត់ត្រាចំនួនតំណក់នៅលើដី ឬ ក្រដាស។

៦- បញ្ឈរសីរ៉ាំងមុខចុះមកក្រោម និងពិនិត្យកំរិតទៅលើកំរិតទឹកលាយនៅលើក្រិតរបស់សីរ៉ាំង។ វាគឺជាចំនួនកំរិតទាំងអស់ ដែលត្រូវលាយទៅក្នុងដបវ៉ាក់សាំង។

៧- យើងគូសចំនុចក្រិតចំនាំ នៅលើសីរ៉ាំងដែលបញ្ជាក់អំពីទំហំទឹកដែលត្រូវលាយ។

ប្រសិនបើចាំបាច់ត្រូវប្រើប្រាស់ ដបបន្តក់ជាកែវ ឬក៏សីរ៉ាំងតូច វិធីខាងលើក៏អាចគណនាបានដែរ ។ ក៏ប៉ុន្តែ ដបបន្តក់ជាកែវ និងសីរ៉ាំងវាមានទំហំតំណក់ធំពេក។ ក្នុងករណីនេះ វាមិនគួរប្រើប្រាស់ឡើយ ។




<u>**ការបង្ហាញអំពីវិធីគណនាលាយវ៉ាក់សាំងឱ្យបានត្រឹមត្រូវ (Alders and Spradbrow 2001)**</u>

## វ៉ាក់សាំងសំរាប់ផឹក

វាជាវិធីសាមញ្ញដើម្បីផ្តល់វ៉ាក់សាំង I2 និង La Sota ប៉ុន្តែវាមានប្រសិទ្ធិភាពតិចតួចណាស់។ នៅពេលដំបូង ដែលវ៉ាក់សាំងនេះត្រូវបានផ្តល់វា ត្រូវចាក់រំលឹក២-៣ សប្តាហ៏ក្រោយ និងបន្ទាប់មកទៀតរៀងរាល់ ៣ខែ។ បង្អត់ទឹករយៈពេលមួយ ទៅពីរម៉ោងមុនពេលយើងឱ្យវាផឹកវ៉ាក់សាំង។ មិនត្រូវលាយជាមួយទឹកមិនស្អាត។ ឱ្យវាផឹកទឹកវ៉ាក់សាំងប្រមាណ ៥-៧ ម.ល។ មិនត្រូវលាងកន្លែងដាក់ទឹកជាមួយថ្នាំសម្លាប់ មេរោគ ឬសាប៊ូ។ នៅតាមជនបទ ជាការជត្រូវឱ្យមាន់ផឹកថ្នាំវ៉ាក់សាំងនៅពេលព្រលឹម ពោលមុនពេលមាន់ចេញពីទ្រុង។

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយគួរតែផ្តល់ដំណឹង និងបញ្ចុះបញ្ចូលអ្នកភូមិអំពីគ្រោះថ្នាក់នៃជម្ងឺញ៉ូកាស និងបញ្ចុះបញ្ចូលពួកគេឱ្យចាក់វ៉ាក់សាំងទៅលើរាល់បក្សី រៀងរាល់៤ខែម្តងជាមួយវ៉ាក់សាំងជម្ងឺញ៉ូកាសជាមួយវ៉ាក់សាំង I2 ។ អ្នកភូមិ ជាអ្នកចេញរាល់ចំណាយលើការធ្វើវ៉ាក់សាំង ។

## វ៉ាក់សាំងជម្ងឺញូកាសដែលត្រូវប្រើនៅកម្ពុជារួចហើយ

ពីមុនមក វិធានការដែលគេនិយមប្រើប្រាស់ គឺការចាក់វ៉ាក់សាំងបក្សីតូចៗ ជាមួយ ND "F" strain (lentogenic) និងបក្សីជំទង់ជាមួយ ND "M" strain (mesogenic) នៃមេរោគញ៉ូកាស ។ វ៉ាក់សាំងទាំងនោះគ្មានភាពធន់ទ្រាំជាមួយកំដៅ និងត្រូវការការថែទាំដោយក្នុងប្រពន្ធ័ត្រជាក់ រហូតដល់កន្លែងចាក់វ៉ាក់សាំង ។ បញ្ហាខ្លះដែលអាចជួបប្រទះជាមួយការខ្វះខាតប្រពន្ធ័ត្រជាក់ ។ យុទ្ធនាការចាក់វ៉ាក់សាំងត្រូវបានធ្វើឡើងនៅរៀងរាល់ឆ្នាំជាច្រើនដង យោងទៅតាមការផ្ទុះជម្ងឺជាញឹកញាប់ ។

## វ៉ាក់សាំងជម្ងឺញូកាសដែលប្រើបច្ចុប្បន្ននៅតំបន់ភាគច្រើនរបស់កម្ពុជា

ពេលបច្ចុប្បន្ននេះ វ៉ាក់សាំងញ៉ូកាស I-2 ត្រូវបាននិយមប្រើប្រាស់ដោយកសិករ ភ្នាក់ងារសុខភាពសត្វភូមិ ពីព្រោះវាមានភាពងាយស្រួលក្នុងការធ្វើវ៉ាក់សាំងចំពោះបក្សីតាមរយៈការបន្តក់ភ្នែក ។ វ៉ាក់សាំងញ៉ូកាស I-2 មានលក់នៅតាមកន្លែងលក់ថ្នាំសត្វខេត្ត និងស្រុក ។ ភ្នាក់ងារសុខភាពសត្វភូមិអាចទិញវ៉ាក់សាំងញ៉ូកាស I-2 និងធ្វើវ៉ាក់សាំងចំពោះមាន់របស់កសិករ ។ វ៉ាក់សាំងនេះត្រូវបានគេប្រើប្រាស់យ៉ាងច្រើននៅកម្ពុជាពេលបច្ចុប្បន្ននេះ ។




**ថ្នាំវ៉ាក់សាំងញ៉ូកាស I-2នាំចូលពីវៀតណាម**

## រដូវកាលនៃការចាក់វ៉ាក់សាំងប្រឆាំងនឹងជម្ងឺញូកាស

មាន់គួរទទួលការចាក់វ៉ាក់សាំងយ៉ាងហោចណាស់ មួយខែមុនជម្ងឺផ្ទុះឡើង។ ជាការប្រសើរត្រូវសួរទៅអ្នកចិញ្ចឹមមាន់ តើនៅពេលណាដែលជាទូទៅជម្ងឺផ្ទុះឡើង ហើយធ្វើផែនការចាក់វ៉ាក់សាំង។ វ៉ាក់សាំងបង្អន់ និិងវ៉ាក់សាំង Lentogenic ផ្ទុកដោយវីរុសញ៉ូកាសដែលមិនអាចសំលាប់មាន់បានទេ ក៏ប៉ុន្តែលក្ខណៈអង់ទីសែនរបស់វាប្រហាក់ប្រហែលនឹងស្រ្តែនរបស់វីរុសដែលបង្កើតបានជាភាពស៊ាំពេញលេញ។

មាន់ដែលបានចាក់វ៉ាក់សាំងរួចហើយ ហើយបានទទួលនូវវីរុសវ៉ាក់សាំងបន្ថែមទៀត មាន់នោះនឹងបង្កើតនូវភាពធន់យ៉ាងឆាប់រហ័ស ហើយអង់ទីគ័រចំពោះជម្ងឺមានកំរិតខ្ពស់។ ភាពស៊ាំនឹងថយចុះ ប្រសិនបើមាន់មិនត្រូវគេចាក់វ៉ាក់សាំងសារជាថ្មីម្តងទៀត។

ជាមួយនឹងការប្រើប្រាស់វ៉ាក់សាំងបន្តក់តាមភ្នែក មាន់គួរធ្វើការចាក់វ៉ាក់សាំងពី ២-៣ ដងក្នុងមួយឆ្នាំ។ ប្រសិនបើប្រើប្រាស់វ៉ាក់សាំងតាមមាត់ កំរិតការពារសត្វបានល្អ និងធានាបានលុះត្រាតែសត្វផ្តល់នូវការចាក់វ៉ាក់សាំងជាលើកទី២ ក្នុងរវាង ២-៤សប្តាហ៍ បន្ទាប់ពីការចាក់វ៉ាក់សាំងលើកទី១ ហើយចាក់ម្តងទៀតក្នុងរវាង ៣ ទៅ ៤ខែ នឹងផ្តល់នូវការការពារដល់សត្វដែលទើបញាស់។

វ៉ាក់សាំងបង្អន់ជាទូទៅត្រូវបានប្រើប្រាស់ក្នុងរវាង ៦ខែម្តង នៅក្នុងតំបន់ណាដែលការផ្ទុះជម្ងឺកើតឡើងមួយឆ្នាំម្តង។ វ៉ាក់សាំងអាចត្រូវប្រើប្រាស់មុនពេលដែលជម្ងឺផ្ទុះឡើង (រដូវផ្ទុះជម្ងឺ)។

ជាបទពិសោធន៍របស់ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការផ្នែកវិស័យចិញ្ចឹមសត្វនៅប្រទេសកម្ពុជា រដូវកាលនៃការចាក់វ៉ាក់សាំងត្រូវបានធ្វើឡើង ២ដងក្នុង១ឆ្នាំទៅតាមការផ្លាស់ប្តូររបស់អាកាស ធាតុ គឺគេចាក់វ៉ាក់សាំងប្រឆាំងនឹងជម្ងឺញ៉ូកាសដូចខាងក្រោមៈ

លើកទី១ នៅចន្លោះពីខែ តុលា-វិច្ឆិកា

លើកទី២ នៅចន្លោះពីខែ មេសា-ឧសភា

ការចាក់វ៉ាក់សាំងបក្សីតូចៗជាមួយ ND "F" strain (lentogenic) និងបក្សីធំទង់ជាមួយ ND "M" strain (mesogenic) នៃមេរោគញ៉ូកាស លែងត្រូវបានគេនិយមប្រើទៀត ហើយដោយសារវ៉ាក់សាំងទាំងនោះគ្មានភាពធន់ទ្រាំជាមួយកំដៅនិងត្រូវការការថែទាំក្នុងប្រព័ន្ធត្រជាក់រហូតដល់កន្លែងចាក់វ៉ាក់សាំង។ បច្ចុប្បន្ននេះការលក់ដូរវ៉ាក់សាំងប្រឆាំងជម្ងឺញ៉ូកាសមានការថយចុះ និងការប្រែប្រួលនៃចំនួនអ្នកចិញ្ចឹមសត្វដោយសារវត្តមានជម្ងឺផ្តាសាយបក្សីដែលបង្កមហន្តរាយដល់ការចិញ្ចឹមបក្សី ក្រុមហ៊ុនថ្នាំសត្វឯកជនបាននាំចូលតែវ៉ាក់សាំងសំរាប់ចាក់បក្សីទាំងតូចនិងបក្សីធំដែលមានឈ្មោះថាវ៉ាក់សាំងញ៉ូកាស Avinew (ផលិតផលបារាំង) និងវ៉ាក់សាំងញ៉ូកាស I-2 (ផលិតផលវៀតណាម)។

<u>កម្មវិធីចាក់វ៉ាក់សាំងជម្ងឺញ៉ូកាសដែលបានប្រើប្រាស់នៅកម្ពុជាកន្លងមក</u>

| **អាយុមាន់** | **ប្រភេទវ៉ាក់សាំង** | **កំរិត** | **វិធីប្រើ** | **ភាពស៊ាំជម្ងឺ** |
|---|---|---|---|---|
| ១-៧ ថ្ងៃ | ជម្ងឺញ៉ូកាសប្រភេទ "F" | ១ -២ តំណក់ | បន្តក់តាមភ្នែក ឬច្រមុះ | ៣ អាទិត្យ |
| ២១ ថ្ងៃ | ជម្ងឺញ៉ូកាសប្រភេទ "F" (ចាក់លើកទី២ប | ១ -២ តំណក់ | បន្តក់តាមភ្នែក ឬច្រមុះ | ៤ ខែ |
| ៤ខែ | ជម្ងឺញ៉ូកាសប្រភេទ "M" | ១-២ ដង | ចាក់ស្លាប | ៦ ខែ- ១ ឆ្នាំ |

<u>កម្មវិធីចាក់វ៉ាក់សាំងជម្ងឺញ៉ូកាសដែលបានប្រើប្រាស់នៅកម្ពុជាពេលបច្ចុប្បន្ន</u>

| **អាយុមាន់** | **ប្រភេទវ៉ាក់សាំង** | **កំរិត** | **វិធីប្រើ** | **ភាពស៊ាំជម្ងឺ** |
|---|---|---|---|---|
| ១-៧ ថ្ងៃ | ជម្ងឺញ៉ូកាសប្រភេទ "ND I2" ឬ AVINEW | ១ -២ តំណក់ | បន្តក់តាមភ្នែក ឬច្រមុះ | ៣ អាទិត្យ |
| ២១ ថ្ងៃ | ជម្ងឺញ៉ូកាសប្រភេទ "ND I2" ឬ AVINEW (ចាក់លើកទី២ប | ១ -២ តំណក់ | បន្តក់តាមភ្នែក ឬច្រមុះ | ៤ ខែ |
| ៤ខែ | ជម្ងឺញ៉ូកាសប្រភេទ "ND I2" ឬ AVINEW | ១-២ តំណក់ | បន្តក់តាមភ្នែក ឬច្រមុះ | ៦ ខែ- ១ ឆ្នាំ |

## ២- ការត្រួតពិនិត្យចលនាសត្វបក្សី

កសិករ មិនត្រូវលក់មាន់ និងបក្សីដទៃទៀតពីកន្លែងដែលមានការងាប់មាន់ និងបក្សីដទៃទៀត។ នៅពេលដែលកសិករចង់លក់មាន់មានសុខភាពល្អរបស់ពួកគេទៅឈ្មួញកណ្តាល មិនត្រូវឱ្យពួកគេចូលទៅក្នុងផ្ទះរបស់អ្នកឡើយ ប្រាប់ពួកគេឱ្យនៅរង់ចាំខាងក្រៅរបង ហើយយកមាន់ដែលអ្នកចង់លក់ទៅឱ្យពួកគេ ពីព្រោះអ្នកមិនដឹងថាតើឈ្មួញកណ្តាលនោះ បានប៉ះពាល់នៅតំបន់ផ្ទុះជម្ងឺ ឬអត់។

- ឈ្មួញលក់មាន់ពីភូមិមួយទៅភូមិមួយទៀត
- ការជល់មាន់
- នៅតំបន់ផ្ទុះជំងឺមិនត្រូវធ្វើចលនាបក្សីឡើយ

- មិនត្រូវទិញបក្សីថ្មី ក្នុងពេលកំពុងផ្ទុះជម្ងឺ ជាពិសេស នៅពេលបក្សីរបស់អ្នកមិនទាន់ចាក់វ៉ាក់សាំង។ អ្នក មិនគួរទិញបក្សីថ្មី កំឡុងពេលរដូវផ្ទុះជម្ងឺញ៉ូកាស។

- ជម្ងឺញ៉ូកាស ជាជម្ងឺមួយឆ្លងបង្កដោយវីរុស ដែលសម្លាប់មាន់នៅក្នុងទ្រុងជាមួយគ្នា ឬនៅក្នុងទ្រុងជិតខាង។ ជាទូទៅ មាន់ឆ្លងជម្ងឺនេះតាមរយៈខ្យល់ ទឹក និងអាហារដែលឆ្លងវីរុសញ៉ូកាស។ វីរុសនេះអាចមាននៅក្នុងខ្យល់ដែលមាន់ដកដង្ហើម និងមានក្នុងវត្ថុរាវរបស់សរីរាង្គ ដូចជាទឹកមាត់ ឈាម និងលាមក។
- មានរបៀបចំលងជាច្រើន ដែលមេរោគញ៉ូកាសអាចចម្លងពីភូមិមួយ ទៅភូមិមួយទៀតដូចជាតាមរយៈមនុស្ស សត្វបក្សីដែលឆ្លងមេរោគ ថ្លដាក់ស៊ុត ចប ទ្រុង និងផលិតផលដែលមានវីរុស (ស៊ុត ស្លាប ឆ្អឹង ពោះវៀន។ល។)
- ឆ្កែ និងឆ្មារអាចឆ្លងមេរោគនេះ ប្រសិនបើវាស៊ីមាន់ងាប់ដោយសារជម្ងឺញ៉ូកាស។
- កាត់បន្ថយការប៉ះពាល់ជាមួយមាន់ និងបក្សីដទៃទៀត ដូចជាទា ព្រាប មាន់បារាំង និងគ្រួច។



## ៣- វិធានការត្រួតពិនិត្យនៅពេលផ្ទុះជម្ងឺ

### ៣.១- ការឃ្លាំមើល

ការឃ្លាំមើលមានន័យថា គឺជាការអង្កេតស្រាវជ្រាវទៅលើសត្វដើម្បីស្វែងរកជម្ងឺ និងមានលទ្ធភាពត្រួតពិនិត្យជម្ងឺ ។

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវពិចារណាពីគ្រប់ជម្ងឺទាំងអស់ និងអត្រាងាប់ដែលកើតមានលើមាន់និងបក្សីដទៃទៀត ។អ្នកភូមិកម្រហៅភ្នាក់ងារសុខភាពសត្វភូមិនិងភ្នាក់ងារផ្សព្វផ្សាយឱ្យមកព្យាបាលមាន់ និងបក្សីដទៃទៀត ប៉ុន្តែភ្នាក់ងារសុខភាពសត្វភូមិ ត្រូវយកចិត្តទុកដាក់ពីពាក្យចចាមអារ៉ាម គួរសម្ភាសន៍អ្នកភូមិនៅពេលទៅព្យាបាលជ្រូក និងគោ ក្របី ឬធ្វើការងារផ្សេងៗនៅ ក្នុងភូមិហើយបញ្ចុះបញ្ចូលឱ្យអ្នកភូមិនិយាយប្រាប់ពីរឿងនេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលបានសំរេចចិត្តឱ្យភ្នាក់ងារសុខភាពសត្វភូមិ ពាក់ព័ន្ធក្នុងការអង្កេតឃ្លាំមើល និងត្រួតពិនិត្យ ជម្ងឺញ៉ូកាសក្នុងភូមិ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលដ៏ជាក់លាក់មួយ ដើម្បីធ្វើការពន្យល់អំពីជម្ងឺនេះដល់កសិករ ។

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវសង្កេតពីស្ថានភាពសត្វជុំវិញពួកគេ។ ប្រសិនបើមាន់ និងបក្សីដទៃទៀតចាប់ផ្តើមឈឺ និងកំពុងងាប់ ពួកគេត្រូវតែសង្ស័យ ។

ការឃ្លាំមើលបានល្អ និងការទប់ស្កាត់បានឆាប់រហ័ស គឺជាការការពារដ៏សំខាន់សំរាប់បក្សីប្រឆាំងនឹងជម្ងឺញ៉ូកាសក្នុងភូមិ ។

## ៤- ការអនុវត្តជីវសុវត្ថិភាពឱ្យកាន់តែប្រសើរ

បន្ទាប់ពីឆ្លងវគ្គបណ្តុះបណ្តាលនេះហើយ ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវប្រាប់អ្នកភូមិពីអ្វី ដែលពួកគាត់ត្រូវធ្វើក្នុងការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ។

១. អ្នកភូមិត្រូវរាយការណ៍ប្រាប់ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយ ប្រសិនបើមានមាន់និងបក្សីដទៃទៀតងាប់ ។

២. អ្នកភូមិត្រូវការពារដៃរបស់ខ្លួនដោយពាក់ស្រោមដៃ ឬថង់ប្លាស្ទិចដើម្បីចាប់កាន់សាកសព ឬមាន់ និងបក្សីដទៃទៀតដែលមានជម្ងឺ។ វិធីល្អបំផុតគឺស្នើសុំជំនួយពីភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយ ។





<u>អ្នកភូមិត្រូវរាយការណ៍ប្រាប់ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយភូមិ</u>

<u>ការពារដៃរបស់អ្នកដោយពាក់ស្រោមដៃ ឬថង់ប្លាស្ទិច</u>

៣- អ្នកភូមិមិនគួរហូបមាន់ និងបក្សីដទៃទៀតមានជម្ងឺ ឬងាប់ទេ ជាពិសេសការធ្វើមាន់ និងបក្សីដទៃទៀត (ការបោចមាន់ និងបក្សីដទៃទៀត និងការវះបក្សី) គឺមានគ្រោះថ្នាក់ខ្លាំងណាស់។ ជួនកាលអ្នកភូមិទិញមាន់ និងបក្សីដទៃទៀតតាមទីផ្សារ ហើយពួកគាត់មិនដឹងថាមាន់ និងបក្សីដទៃទៀត ទាំងនោះមានសុខភាពល្អ ឬអត់ទេដូច្នេះពួកគេត្រូវប្រយត្ន័នៅពេលគេយកមាន់ និងបក្សីដទៃទៀតទៅធ្វើម្ហូប។ ចូរដាក់មាន់ និងបក្សីដទៃទៀតចូលក្នុងទឹកក្តៅ និងការពារមុខរបស់អ្នកដោយប្រើក្រមា និងលាងដៃ កាំបិត ឱ្យបានស្អាតដោយប្រើសាប៊ូ។

៤- បន្ទាប់ពីប្រមូលសាកសពរួច អ្នកភូមិត្រូវកប់ ឬដុតកំទេចចោល **ជៀសវាងកុំ បោះចោលមាន់ និងបក្សីដទៃទៀត ងាប់ពាសវាលពាសកាលឱ្យសោះ ហើយមិនត្រូវយក សាកសពមាន់ និងបក្សីដទៃទៀត ទៅឱ្យជ្រូកស៊ីឱ្យសោះ** ពីព្រោះមាន់ និងបក្សីដទៃទៀតងាប់ គឺពោរពេញទៅដោយវីរុស។





<u>**កុំទិញមាន់ និងបក្សីដទៃទៀតដែលពុំដឹងប្រភពច្បាស់លាស់**</u>

<u>**កុំបោះចោលមាន់ និងបក្សីដទៃទៀតងាប់ពាសវាលពាសកាល**</u>

៥- អ្នកភូមិត្រូវសំអាតបរិវេណជុំវិញផ្ទះ ប្រមូលលាមក និងស្លាប ហើយយកទៅកប់។ កុំបោះវាចោលឱ្យសោះ ពីព្រោះមានវីរុសផ្តាសាយបក្សីនៅតែមានក្នុងលាមក និងស្លាបរបស់មាន់ និងបក្សីដទៃទៀត ប្រសិនបើអ្នកបោះវាចោល វានឹងឆ្លងរាលដាលជុំវិញផ្ទះ របស់អ្នក។








**ដុត ឬកប់មាន់ និងបក្សីដទៃទៀតងាប់ និងកាកសំណល់ក្នុងរណ្តៅ**

៦. អ្នកភូមិមិនត្រូវចិញ្ចឹមមាន់ និងបក្សីដទៃទៀតក្រោមផ្ទះ សង់ទ្រុងមាន់ និងបក្សីដទៃទៀតឱ្យឆ្ងាយពីផ្ទះ។

៧. អ្នកភូមិមិនត្រូវចិញ្ចឹមមាន់ និងបក្សីដទៃទៀតនៅតាមវាល តាមបឹង អូរ ឬ ស្ទឹង ត្រូវធ្វើរបងខណ្ឌឱ្យបានត្រឹមត្រូវ។



<u>**មិនត្រូវចិញ្ចឹមមាន់ និងបក្សីដទៃទៀតក្រោមផ្ទះ**</u>



<u>**មិនត្រូវចិញ្ចឹមទានៅតាមអូរ**</u>

៨- អ្នកភូមិមិនត្រូវចិញ្ចឹមមាន់ និងបក្សីដទៃទៀតច្របូកច្របល់គ្នា។



<u>**ចិញ្ចឹមមាន់តែមួយប្រភេទ**</u>



<u>**ចិញ្ចឹមទាតែមួយប្រភេទ**</u>

៩- នៅពេលមានមាន់ និងបក្សីដទៃទៀតងាប់ អ្នកភូមិត្រូវស្នើសុំឱ្យភ្នាក់ងារសុខភាពសត្វភូមិ បាញ់

ថ្នាំសម្លាប់មេរោគ។ ថ្នាំនេះមិនគិតថ្លៃអ្វីទេ។ ថ្នាំសម្លាប់មេរោគនេះមានប្រសិទ្ធិភាពណាស់ ក្នុងការសម្លាប់វីរុសនានា។ វាកាន់តែមានប្រសិទ្ធិភាពប្រសិនបើប្រើ នៅលើផ្ទៃដីដែលស្អាត។



<u>ភ្នាក់ងារសុខភាពសត្វភូមិបាញ់ថ្នាំសម្លាប់មេរោគ</u>

១០- មុនពេលដាក់មាន់និងបក្សីថ្មីចូលចិញ្ចឹមអ្នកភូមិត្រូវទុកវាដាច់ដោយឡែកពីមាន់និងបក្សីចាស់យ៉ាងហោច ១៤ថ្ងៃ។






<u>ដាក់មាន់ និងបក្សីថ្មីឱ្យនៅដាច់ដោយឡែកពីមាន់ និងបក្សីចាស់យ៉ាងហោច១៤ថ្ងៃ</u>

១១- អ្នកភូមិត្រូវលាងដៃនឹងសាប៊ូឬផេះរៀងរាល់ពេលមុន និងក្រោយពេលកាន់មាន់ និងបក្សីដទៃទៀត ។




<u>លាងដៃនឹងសាប៊ូ ឬផេះរៀងរាល់ពេលមុន និងក្រោយពេលកាន់មាន់ និងបក្សីដទៃទៀត</u>

១២- លាងសំអាត សម្លាប់មេរោគលើសម្ភារៈប្រើប្រាស់ក្រោយពីបញ្ចប់ការងារ



<u>លាងសំអាត សម្លាប់មេរោគលើសម្ភារៈប្រើប្រាស់ក្រោយពីបញ្ចប់ការងារ</u>

☞ **សារសំខាន់ៗដែលអ្នកភូមិត្រូវចងចាំៈ**

១. អ្នកភូមិត្រូវរាយការណ៍ប្រាប់ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយប្រសិនបើមានមាន់ និងបក្សីដទៃទៀតងាប់។

២. អ្នកភូមិត្រូវការពារដៃរបស់ខ្លួនដោយពាក់ស្រោមដៃ ឬថង់ប្លាស្ទិចដើម្បីចាប់កាន់សាកសព ឬមាន់ និង បក្សីដទៃទៀតមានជម្ងឺ។ វិធីល្អបំផុត គឺស្នើសុំជំនួយពីភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយ។

៣. អ្នកភូមិមិនត្រូវបរិភោគមាន់ និងបក្សីដទៃទៀតឈឺ ឬងាប់។

៤. អ្នកភូមិត្រូវកប់ ឬដុតរៀងរាល់ពេលមានមាន់ និងបក្សីដទៃទៀតងាប់។

៥. អ្នកភូមិត្រូវបោសសំអាតទីធ្លាជុំវិញរៀងរាល់ថ្ងៃ។

៦. អ្នកភូមិមិនត្រូវចិញ្ចឹមមាន់ និងបក្សីដទៃទៀតក្រោមផ្ទះ សង់ទ្រុងមាន់ និងបក្សីដទៃទៀតឱ្យ ឆ្ងាយពីផ្ទះ។

៧. អ្នកភូមិមិនត្រូវចិញ្ចឹមមាន់ និងបក្សីដទៃទៀតនៅតាមវាល តាមបឹង អូរ ឬស្ទឹង ត្រូវធ្វើរបងខណ្ឌឱ្យបានត្រឹមត្រូវ។

៨. អ្នកភូមិមិនត្រូវចិញ្ចឹមមាន់និងបក្សីដទៃទៀតជាមួយគ្នា។

៩. នៅពេលមានមាន់ និងបក្សីដទៃទៀតងាប់ អ្នកភូមិត្រូវរាយការណ៍មកភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វ ផ្សាយ។

១០. មុនពេលដាក់មាន់ និងបក្សីថ្មីចូលចិញ្ចឹម អ្នកភូមិត្រូវទុកវាដាច់ដោយឡែកពី មាន់ និងបក្សីចាស់ យ៉ាងហោច១៤ថ្ងៃ។

១១. អ្នកភូមិត្រូវលាងដៃនឹងសាប៊ូ ឬផេះមុន និងក្រោយប៉ះពាល់ជាមួយមាន់ និង បក្សីដទៃទៀត។

១២. អ្នកភូមិត្រូវលាងសំអាតរំងាប់មេរោគលើសម្ភារៈប្រើប្រាស់ ក្រោយពីបញ្ចប់ការងារ។

## ៥- ការរាយការណ៍

ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវរាយការណ៍ឱ្យបានល្អពីការអង្កេត និង សកម្មភាពនានា ទៅកាន់ពេទ្យសត្វស្រុក។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាល មជ្ឈមណ្ឌលជាតិស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាល ត្រូវដឹងថាមានអ្វីកើតឡើង ពាក់ព័ន្ធទៅនឹងសុខភាពសត្វក្នុងភូមិ។ ក្រសួង នាយកដ្ឋាន និងមជ្ឈមណ្ឌលចាំបាច់ត្រូវមានព័ត៌មានដែល បានមកពីមូលដ្ឋានផ្ទាល់ដើម្បីដឹងថាតើមានជម្ងឺធំៗអ្វីខ្លះក្នុងប្រទេសកម្ពុជា និងរៀបចំផែនការមួយចំនួន ដើម្បីពង្រឹងសុខភាពសត្វ ផ្តល់ការណែនាំស្តីពីការព្យាបាល និងរៀបចំបង្កើតកម្មវិធីចាក់វ៉ាក់សាំង។

ជាពិសេស ត្រូវយកចិត្តទុកដាក់លើជម្ងឺញ៉ូកាស ពីព្រោះជម្ងឺនេះធ្វើឱ្យងាប់មាន់ជាច្រើនក្បាល ក្នុងភូមិ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដឹងឱ្យច្បាស់ពីសភាពការណ៍ជម្ងឺនៅក្នុងប្រទេស។

ម្យ៉ាងវិញទៀត ជម្ងឺញ៉ូកាសអាចជាមូលហេតុចំបងមួយនៃភាពក្រីក្រនៅក្នុងភូមិដែលបំផ្លាញផ្នួនៗដល់ការចិញ្ចឹមមាន់ និងបក្សីដទៃទៀតជាលក្ខណៈគ្រួសារ។

- ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវធ្វើរបាយការណ៍ពីការងាប់មាន់ និងបក្សីដទៃទៀតក្នុងសៀវភៅកត់ត្រាជាក់លាក់មួយដែលផ្តល់ដោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល (ការកត់ត្រាពីសត្វងាប់ប្រភេទផ្សេងៗទៀតក៏មានសារៈសំខាន់ដែរ)។

- **ប្រសិនបើគ្មានបញ្ហាធ្ងន់ធ្ងរទេ** ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវផ្តល់របាយការណ៍ថតចម្លង ២ច្បាប់ទៅពេទ្យសត្វស្រុកនៅពេលប្រជុំប្រចាំខែ។ ១ ច្បាប់ទុកនៅថ្នាក់ស្រុក និង ១ច្បាប់ទៀតត្រូវបញ្ជូនទៅកាន់ មជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល។

- **ប្រសិនបើមានបញ្ហាធ្ងន់ធ្ងរ** មានមាន់ និងបក្សីដទៃទៀតឈឺ ឬងាប់ ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយ ត្រូវផ្តល់ព័ត៌មានសំខាន់ៗទាំងអស់ទៅពេទ្យសត្វស្រុក ដែលគាត់នឹងជូនដំណឹងទៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល។

- បុគ្គលិករបស់មជ្ឈមណ្ឌលជាតិស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាលត្រូវការព័ត៌មានគួរឱ្យជឿជាក់បានៈ

+ មុនពេលចុះមកដល់ភូមិ ដើម្បីផ្តល់ការគាំទ្រដល់បុគ្គលិកតាមមូលដ្ឋាន

+ កត់ត្រាព័ត៌មាននិងដឹងច្បាស់ពីស្ថានភាពជម្ងឺញ៉ូកាសនៅក្នុងប្រទេស

+ធ្វើការត្រួតពិនិត្យថា តើភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយរាយការណ៍ត្រឹមត្រូវដែរឬទេ?

**របៀបធ្វើរបាយការណ៍ត្រឹមត្រូវ**

- ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវកត់ត្រាៈ

+ កន្លែងដែលមានការងាប់មាន់ និងបក្សីដទៃទៀតកើតឡើង

+ ថ្ងៃខែឆ្នាំដែលការងាប់មាន់ និងបក្សីដទៃទៀតចាប់ផ្តើមកើតឡើង

+ តើមានមាន់ និងបក្សីដទៃទៀតប៉ុន្មានដែលបានងាប់ក្នុងចំណោម មាន់ និងបក្សីដទៃទៀតសរុបទាំងអស់

+ ពិពណ៌នាថា តើការងាប់នោះមានលក្ខណៈធ្ងន់ធ្ងរដែរឬទេ និងរៀបរាប់ពីរោគ សញ្ញាផងដែរ

+ តើការឆ្លើយតបសំរេចបានជាក់ស្តែងនូវអ្វីខ្លះ : កប់ បាញ់ថ្នាំសម្លាប់មេរោគ ។ល។

+ ថ្ងៃ ខែ ឆ្នាំដែលការងាប់លែងកើតមាន។

ភ្នាក់ងារសុខភាពសត្វភូមិ នឹងទទួលបានសៀវភៅកត់ត្រាជាក់លាក់មួយ ដែលមានគោលការណ៍ណែនាំ ជួយឱ្យការធ្វើរបាយការណ៍មានភាពត្រឹមត្រូវ។ រាល់របាយការណ៍ទាំង អស់ត្រូវថតចម្លងចំនួន ៣ សន្លឹក ក្នុងនោះមួយច្បាប់សំរាប់ពេទ្យសត្វស្រុកមួយច្បាប់ទៀត សំរាប់មជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល និងមួយច្បាប់ចុងក្រោយសំរាប់ភ្នាក់ងារសុខភាពសត្វភូមិខ្លួនឯង។ គាត់ត្រូវរក្សាសៀវភៅកត់ត្រានេះទុកសំរាប់រយៈពេល ១ឆ្នាំ។

ភ្នាក់ងារសុខភាពសត្វភូមិ មិនអាចរង់ចាំការបញ្ជាក់លើរោគវិនិច្ឆ័យ ដោយមន្ទីរពិសោធន៍របស់មជ្ឈមណ្ឌលជាតិស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាល ដើម្បីអនុវត្តវិធានការត្រួតពិនិត្យទប់ស្កាត់បានទេ។ ត្រូវរាយកាណ៍ទៅកាន់អាជ្ញាធរ ប្រមូលវត្ថុវិភាគ។ ការវិភាគក្នុងមន្ទីរពិសោធន៍ និងការបញ្ជាក់លើលទ្ធផល នឹងចំណាយពេលប្រហែល ៥ថ្ងៃ។ វានឹងមានការយឺតយ៉ាវណាស់ក្នុងការសំរេចឱ្យបាននូវការទប់ស្កាត់ប្រកបដោយប្រសិទ្ធិភាពនោះ។ ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវបញ្ឈប់ជម្ងឺញ៉ូកាសដ៏គួរឱ្យសង្ស័យឱ្យបានភ្លាមៗ។

⇨ ប្រសិនបើអ្នករង់ចាំលទ្ធផលពីមន្ទីរពិសោធន៍ នោះស្ថានភាពជម្ងឺនឹងពិបាកទប់ស្កាត់!!!

- ភ្នាក់ងារសុខភាពសត្វភូមិត្រូវចុះទៅពិនិត្យផ្ទះនោះជារៀងរាល់ថ្ងៃឱ្យបានរយៈពេល៥ថ្ងៃ ដើម្បីពិនិត្យមើលថាតើមាន់ ទាឈប់ងាប់ ឬមានងាប់ជាបន្តបន្ទាប់ទៅទៀត។ ភ្នាក់ងារសុខភាព សត្វភូមិត្រូវចុះទៅត្រួតពិនិត្យជាបន្តបន្ទាប់ទៀតរហូតដល់មាន់ ទាលែងមានងាប់ និងត្រូវអង្កេត ផងដែរមាន់ទារបស់អ្នកជិត ខាង។
- ភ្នាក់ងារសុខភាពសត្វភូមិនឹងចុះធ្វើការត្រួតពិនិត្យទប់ស្កាត់ (ប្រមូលវត្ថុវិភាគ និងបាញ់ថ្នាំសំលាប់មេរោគ។ល។) ប៉ុន្តែគាត់ត្រូវចុះទៅពិនិត្យកសិដ្ឋាននោះម្តងទៀតដើម្បីពិនិត្យមើលថា តើការ ងាប់មាន់ ទា ឈប់មានហើយឬនៅ និងចុះទៅពិនិត្យផ្ទះដែលនៅជិតខាង ដើម្បីឱ្យដឹងថាតើមានការងាប់ ឬ អត់។ ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវធ្វើការឱ្យលឿនជាងមេរោគរាលដាល។
- ប្រសិនបើមានអត្រាងាប់ខ្ពស់ ភ្នាក់ងារសុខភាពសត្វភូមិ តូវជូនដំណឹងដល់ពេទ្យសត្វស្រុកភ្លាមៗផងដែរ។

## ៦- អប់រំអ្នកភូមិពីជម្ងឺញ៉ូកាស (ការអប់រំសាធារណជន)

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយ ត្រូវបញ្ចុះបញ្ចូលអំពីគ្រោះថ្នាក់នៃជម្ងឺញ៉ូកាសដើម្បីបញ្ចុះបញ្ចូលពួកគេឱ្យរាយការណ៍ពីការងាប់មាន់ និងទទួលយកវិធានការណ៍ការពារក្នុងពេលមានផ្ទុះជម្ងឺ។

**រៀបចំការប្រជុំ ដើម្បីជូនដំណឹងដល់អ្នកភូមិ**

១. រៀបចំការប្រជុំក្នុងភូមិជាមួយនឹងប្រធានភូមិ ឬចុះតាមផ្ទះនីមួយៗ ដើម្បីជូនព័តិមាន ដល់ក្រុមគ្រួសារទាំងអស់ឱ្យដឹងពីស្ថានការណ៍នេះ។ ប្រសិនបើគេបានជូនព័តិមានដល់អ្នកភូមិជាមុននោះ វានឹងមានភាពងាយស្រួល ក្នុងការបញ្ចុះបញ្ចូលពួកគេឱ្យគោរពតាមបទបញ្ជា។

២. សហការជាមួយមេភូមិ ដើម្បីទប់ស្កាត់ចលនាបក្សីចេញ និងចូលក្នុងភូមិកំឡុងពេលរង់ចាំលទ្ធផលពីមន្ទីរពិសោធន៍។

៣. កសិករដែលចិញ្ចឹមសត្វតាមបែបប្រពលវប្បកម្មត្រូវទុកមាន់ ទា និងបក្សីដទៃទៀតនៅក្នុងទ្រុង ឬ ផ្ទះដែលមានស្តុកទឹកស្អាត មានការផ្តល់ចំណីគ្រប់គ្រាន់ និងចាក់វ៉ាក់សាំងជាទៀងទាត់ប្រឆាំងនឹងជម្ងឺញ៉ូកាស ហ្គុមបូរ និងជម្ងឺប៉េស្តទាទៅប្រភេទរបស់សត្វ។

៤. កសិករដែលចិញ្ចឹមមាន់ព្រលែង ត្រូវបំបែកមាន់ ទា និងបក្សីដទៃទៀតនៅក្នុងទ្រុងផ្សេងៗគ្នានៅពេលយប់ និងចាក់វ៉ាក់សាំងប្រឆាំងនឹងជម្ងឺញ៉ូកាសជាទៀងទាត់ ។ ទ្រុងត្រូវរក្សាឱ្យស្អាតជានិច្ច ហើយលាមកត្រូវ រក្សាក្នុងរណ្តៅធ្វើជីរកំប៉ុស្ត មុនពេលយកវាទៅប្រើប្រាស់នៅតាមវាល ។

ប្រជាពលរដ្ឋតែងចង់សន្សំប្រាក់ និងព្យាយាមលក់មាន់ និងទាឱ្យបានមុនពេលដែលនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលបង្គាប់ឱ្យសំលាប់ពួកវា ។ វាមានគ្រោះថ្នាក់ខ្លាំងណាស់ ពីព្រោះថាមាន់ និងទាទាំងនេះអាចចម្លងវីរុសដល់បណ្តាភូមិផ្សេងទៀត ។

បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលរួច ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវផ្សព្វផ្សាយបន្តដល់អ្នកភូមិៈ

- ✵ ភ្នាក់ងារសុខភាពសត្វភូមិនិងភ្នាក់ងារផ្សព្វផ្សាយត្រូវប្រាប់អ្នកភូមិមិនឱ្យហូបមាន់និងបក្សីដទៃទៀតឈឺ ឬងាប់ ។ ជាពិសេសការធ្វើមាន់និងបក្សីដទៃទៀត (ការបោចសត្វមាន់ និងបក្សីដទៃទៀត, ការវះបក្សី) គឺវាមានគ្រោះថ្នាក់ណាស់ ។






<u>មិនត្រូវហូប មាន់ និងបក្សីដទៃទៀតឈឺ ឬងាប់</u>

- ✵ ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវផ្តល់ដំណឹងដល់អ្នកភូមិ ដើម្បីឱ្យពួកគេដឹងពីជម្ងឺញ៉ូកាស ។ វិធីល្អបំផុត គឺពិភាក្សាជាមួយអ្នកភូមិនៅពេលទៅព្យាបាលជ្រូក ។ វាកាន់តែងាយស្រួលក្នុងការបញ្ចុះបញ្ចូលមនុស្សនៅពេលបានពិភាក្សាទល់មុខជាមួយគ្នា ។






<u>ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយអប់រំណែនាំដល់អ្នកភូមិពីជម្ងឺញ៉ូកាស</u>

❋ អ្នកត្រូវពិភាក្សា និងផ្ដល់ដំណឹងដល់ប្រធានភូមិឱ្យបានច្បាស់លាស់អំពីភារកិច្ចថ្មីជាអ្នកផ្សព្វផ្សាយជម្ងឺញ៉ូកាស ពីព្រោះអ្នកនឹងត្រូវការការគាំទ្រពីគាត់ក្នុងការបំពេញការងាររបស់អ្នក។ ជាការពិតណាស់នៅពេលមានគ្រួសារប្រឈមមុខការងាប់មាន់ និងបក្សីដទៃទៀតអ្នកត្រូវផ្ដល់ព័ត៌មានម្ដងហើយម្ដងទៀត ពីព្រោះពេលខ្លះ ពួកគេអាចភ្លេចដំបូន្មានរបស់អ្នក។



<u>ការពិភាក្សា និងផ្ដល់ដំណឹងដល់ប្រធានភូមិ</u>

❋ **អ្នកត្រូវពន្យល់ព័ត៌មាននានាឱ្យបានច្បាស់លាស់:** រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ និងនៅពេលក្រោយមិនត្រូវភ្លេចជម្ងឺញ៉ូកាសទេ។ នៅពេលអ្នកប្រឈមមុខនឹងមាន់ និងបក្សីដទៃទៀតងាប់ និងមិនត្រូវ ភ្លេចថាជម្ងឺញ៉ូកាសអាចមានកើតឡើងគ្រប់ពេលវេលា។

❋ ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវមានការប្រុងប្រយ័ត្នពិសេស នៅពេលអ្នកភូមិប្រារព្ធពិធីអាពាហ៍ពិពាហ៍។ ពេលនោះបងប្អូនសាច់ញាតិយកមាន់មកពីភូមិជាច្រើន ហើយអាចមានមាន់ ខ្លះឆ្លងជម្ងឺផងដែរ។ ចូរប្រាប់ប្រជាជនម្ដងទៀត ដើម្បីឱ្យពួកគេធ្វើការរៀបចំឱ្យមានជីវសុវត្ថិភាព និងដឹង ពីគ្រោះថ្នាក់ប្រឈមមុខជាមួយជម្ងឺញ៉ូកាស។

❋ ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវតែបញ្ចុះបញ្ចូលអ្នកភូមិ ដើម្បីឱ្យពួកគេប្រាប់ពីការងាប់មាន់ និងបក្សីដទៃទៀតក្នុងភូមិ។

❋ ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវតែបញ្ចុះបញ្ចូលអ្នកភូមិឱ្យយល់ថា: ការលក់សត្វមាន់ និងបក្សីដទៃទៀតឈឺ ឬងាប់ នឹងសន្សំសំចៃប្រាក់ខ្លះមែន ប៉ុន្តែពួកគេនឹងធ្វើឱ្យជម្ងឺនេះរាលដាល ទៅភូមិដទៃទៀត។

តើត្រូវធ្វើអ្វីខ្លះប្រសិនបើអ្នកភូមិមិនជឿ

១. មិនមែនជារឿងងាយស្រួលនោះទេ ក្នុងការបញ្ចុះបញ្ចូលអ្នកភូមិឱ្យគាត់ជឿតាម ដោយសារពួកគាត់ធ្លាប់ប្រឈមមុខនឹងការងាប់សត្វមាន់ និងបក្សីដទៃទៀតជារឿយៗ និងធ្លាប់បរិភោគ សត្វមាន់ និងបក្សីដទៃទៀតឈឺ ឬងាប់ ពួកគាត់នឹងនិយាយថា ពួកគាត់មិនដែលជួបប្រទះបញ្ហាសុខភាពម្តងណា ឡើយរហូតមកទល់ពេលបច្ចុប្បន្ននេះ។

២. អ្នកភូមិក្រីក្រគ្មានប្រាក់ទិញអាហារសាច់ផ្សេងទៀតទេ ជាពិសេសអាហារដែល មានប្រូតេអ៊ីនហើយពួកគេចង់បរិភោគសាច់មាន់ និងបក្សីដទៃទៀតប្រសិនបើគេ បញ្ចុះតំលៃចំពោះមាន់ និងបក្សីដទៃទៀតឈឺ ឬងាប់ ពួកគាត់នឹងទិញ។

៣. មនុស្សសំខាន់ៗខ្លះ ឬអ្នកមាននៅក្នុងភូមិ នឹងមិនធ្វើតាមដំបូន្មានរបស់អ្នកទេ ដោយពួកគេមានឋានៈខ្ពស់ជាង។

តើត្រូវធ្វើការបញ្ចុះបញ្ចូលដោយរបៀបណា?

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវមកជួបគ្រួសារទាំងនេះឱ្យបានច្រើនដង និងពិភាក្សា ជាមួយគាត់ម្តងហើយម្តងទៀត។ ពួកគេត្រូវការពេលវេលាដើម្បីធ្វើការផ្លាស់ប្តូរ ឥរិយាបថ ហើយវាមានសារៈសំខាន់ណាស់ក្នុងការព្យាយាមបញ្ចុះបញ្ចូលជាច្រើនដង។ ពួកគេនឹងគិតថា ដំបូន្មានរបស់អ្នកនឹងមានសារៈសំខាន់ ប្រសិនបើអ្នកមិនបញ្ឈប់នូវការព្យាយាមបញ្ចុះបញ្ចូលរបស់អ្នកទេនោះ ។ អ្នកអាចស្នើសុំការគាំទ្រពីមេភូមិ។

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយអាចស្នើសុំការគាំទ្ររបស់ពេទ្យសត្វស្រុក ឬខេត្ត ដើម្បីបញ្ចុះបញ្ចូលឱ្យមនុស្សសំខាន់ៗនៅក្នុងភូមិជឿ។

**<u>ត្រូវចងចាំ</u>**

- ការផ្តល់ព័ត៌មាន គឺជាវិធីដ៏ល្អសំរាប់ឱ្យអ្នកភូមិយល់ដឹងពីជម្ងឺញ៉ូកាស ។
- ប្រធានភូមិ គឺជាមនុស្សសំខាន់ដែលនឹងពាក់ពន្ធ័ជាមួយនឹងការងាររបស់អ្នក ។
- មិនត្រូវភ្លេចនូវការប្រុងប្រយ័ត្នពិសេស នៅពេលអ្នកភូមិប្រារព្ធពិធីអាពាហ៍ពិពាហ៍ ពេលនោះបងប្អូនសាច់ ញាតិ យកមាន់មកពីភូមិជាច្រើន ហើយអាចមានមាន់ខ្លះឆ្លងជម្ងឺផង ដែរ ។
- ត្រូវគិតថានៅពេលមានមាន់ និងបក្សីដទៃទៀតងាប់ ជម្ងឺញ៉ូកាសនឹងអាចកើតមានឡើង ។
- ដើម្បីត្រួតពិនិត្យ និងការពារទប់ស្កាត់ជម្ងឺញ៉ូកាសនៅតាមភូមិ ភ្នាក់ងារសុខភាពសត្វភូមិមានភារកិច្ច ចំបង ៥ដែលត្រូវធ្វើគឺៈ

  ១- ចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំង

  ២- អង្កេត (ឃ្លាំមើល)

  ៣-ត្រួតពិនិត្យ និងរបាយការណ៍

  ៤- បញ្ឈប់ជម្ងឺ

  ៥- ផ្តល់ដំណឹង និងបញ្ចុះបញ្ចូល

## គ. តួនាទីភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយភូមិក្នុងការត្រួតពិនិត្យ ជម្ងឺញ៉ូកាស

នាពេលបច្ចុប្បន្ននេះ ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយទទួលខុសត្រូវក្នុងការព្យាបាលសត្វ ក្នុងភូមិនៅពេលសត្វមានជម្ងឺ។ ពួកគេរស់នៅ និងធ្វើការនៅក្នុងភូមិ ហើយពួកគេចុះទៅពិិនិត្យតាមផ្ទះនានានៅក្នុងភូមិ។ ដូច្នេះពួកគេដឹងថាមានអ្វីកើតឡើងលើសុខភាពរបស់សត្វនៅ ក្នុងភូមិ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល បានសំរេចចិត្តឱ្យភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយចូលរួមពាក់ព័ន្ធក្នុង **ការអង្កេតឃ្លាំមើល និងត្រួតពិនិត្យ** ជម្ងឺញ៉ូកាសក្នុងភូមិ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលដ៏ជាក់លាក់មួយ ដើម្បីធ្វើការពន្យល់អំពីជម្ងឺនេះ និងធ្វើការពន្យល់អំពីការងារផ្សេងៗឱ្យបានច្បាស់ដែលត្រូវសំរេចឱ្យបានដោយភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយ ។

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយនឹងផ្តល់ព័ត៌មាន **និងបញ្ចុះបញ្ចូល** អ្នកភូមិឱ្យយល់ពីគ្រោះថ្នាក់ប្រឈមមុខនៃជម្ងឺញ៉ូកាស ដើម្បីលើកទឹកចិត្តឱ្យពួកគេរាយការណ៍ពីអត្រាងាប់ មាន់ និងបក្សី ដទៃទៀត និងទទួលយកវិធានការទប់ស្កាត់ក្នុងករណីមានជម្ងឺផ្ទុះឡើង។

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវរាយការណ៍ឱ្យបានល្អពីការអង្កេត និង សកម្មភាពនានាទៅកាន់ពេទ្យសត្វស្រុក។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល មជ្ឈមណ្ឌលជាតិស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាល ត្រូវដឹងថាមាន អ្វីកើតឡើងពាក់ព័ន្ធទៅនឹងសុខភាពសត្វក្នុងភូមិ។ ក្រសួង នាយកដ្ឋាន និងមជ្ឈមណ្ឌល ចាំបាច់ត្រូវមានព័ត៌មានដែលបានមកពីមូលដ្ឋានផ្ទាល់ ដើម្បីដឹងថាតើមានជម្ងឺធំៗអ្វីខ្លះក្នុងប្រទេសកម្ពុជា និងរៀបចំផែនការមួយចំនួនដើម្បីពង្រឹងសុខភាពសត្វផ្តល់ការណែនាំស្តីពីការព្យាបាល និងរៀបចំបង្កើតកម្មវិធីចាក់វ៉ាក់សាំង។

ជាពិសេសត្រូវយកចិត្តទុកដាក់លើជម្ងឺញ៉ូកាស ពីព្រោះជម្ងឺនេះមានលក្ខណៈគ្រោះថ្នាក់ខ្លាំងណាស់ៈ វាអាចសម្លាប់មនុស្ស និងឆ្លងរាលដាលទូទាំងពិភពលោក។ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវដឹងឱ្យច្បាស់ពីសភាពការណ៍ជម្ងឺនៅក្នុងប្រទេស។

ម្យ៉ាងវិញទៀត ជម្ងឺញ៉ូកាស អាចជាមូលហេតុចំបងមួយនៃភាពក្រីក្រនៅក្នុងភូមិដែលបំផ្លាញ ផ្នួនៗដល់ការចិញ្ចឹមមាន់ និងបក្សីដទៃទៀតជាលក្ខណៈគ្រួសារ។

**ត្រូវចងចាំ**

ការត្រួតពិនិត្យជម្ងឺមានន័យថាជាសកម្មភាពមួយដែលមានបំណងការពារទប់ស្កាត់ ដើម្បីកាត់បន្ថយជម្ងឺ ឬធ្វើឱ្យជាសះស្បើយឡើងវិញ។ តួនាទីរបស់ភ្នាក់ងារសុខភាពភូមិ ក្នុងការត្រួតពិនិត្យជម្ងឺញ៉ូកាសមាន៖

+ ចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំង
+ ការអង្កេតឃ្លាំមើល និងការត្រួតពិនិត្យ
+ ការផ្តល់ព័ត៌មាន និងការបញ្ចុះបញ្ចូល
+ ការធ្វើរបាយការណ៍

## ឃ. តើភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវធ្វើអ្វីខ្លះ?

នៅពេលភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយកត់សំគាល់ពីមាន់ និងបក្សីដទៃទៀតងាប់ដ៏គួរឱ្យង្ស័យនោះ គាត់មិនអាចប្រាកដច្បាស់ថា តើវាគឺជាជម្ងឺញ៉ូកាសទេបើសិនជាគ្មាន ការវិភាគនៅមន្ទីរពិសោធន៍។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយវាមានសារៈសំខាន់ក្នុងការបញ្ឈប់ ការឆ្លងរាលដាលជម្ងឺនេះភ្លាមៗ ដើម្បីបង្ការកុំឱ្យមាន់ និងបក្សីដទៃទៀតឈឺនៅក្នុងភូមិ និងជៀសវាងការឆ្លងរាលដាលទៅភូមិដទៃទៀត។

នៅពេលភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយកត់សំគាល់ពីមាន់ និងបក្សីដទៃទៀតងាប់ដ៏គួរឱ្យសង្ស័យ នោះគាត់ត្រូវអនុវត្តតាមគោលការណ៍សំខាន់ខាងក្រោមនេះ

| អង្កេតឃ្លាំមើល | ➔ | ត្រួតពិនិត្យ + របាយការណ៍ | ➔ | បញ្ឈប់ជម្ងឺ |
|---|---|---|---|---|



<u>ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយចុះទៅពិនិត្យកន្លែងមាន់ និងបក្សីដទៃទៀតឈឺ ឬងាប់</u>

### ១- ការអង្កេតឃ្លាំមើល

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវអង្កេតជានិច្ចកាលលើសត្វជុំវិញខ្លួន។ ប្រសិនបើមាន់ និងបក្សីដទៃទៀតចាប់ផ្តើមឈឺ និងកំពុងងាប់ គាត់ត្រូវសង្ស័យភ្លាម។

## ២- ការត្រួតពិនិត្យ និងរបាយការណ៍

- នៅពេលដែលភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវបានជូនដំណឹងពីមាន់ និងបក្សីដទៃទៀតងាប់នៅផ្ទះមួយ គាត់ត្រូវទៅមើលជាបន្ទាន់កន្លែងនោះដើម្បីឱ្យដឹងពីមាន់ និងបក្សីដទៃទៀតដែលបានងាប់ និង ចំនួនមាន់ និងបក្សីដទៃទៀតឈឺ ។
- ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវតែរាយការណ៍ទៅកាន់ពេទ្យសត្វស្រុក ឬមជ្ឈមណ្ឌល ជាតិស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាលអំពីការងាប់មាន់ និងបក្សី ដទៃទៀត ។
- ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវរាយកាណ៍ពីការអង្កេតលើការងាប់មាន់ និងបក្សីដទៃទៀតទៅកាន់ពេទ្យសត្វស្រុក ខេត្ត ឬក៏មជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល ។ គាត់ត្រូវទៅពិនិត្យផ្ទះដែលមានមាន់ និងបក្សីដទៃទៀតឈឺ ឬងាប់ជាប្រចាំ ។ មជ្ឈមណ្ឌលជាតិស្រាវជ្រាវ ផលិតកម្ម និងបសុព្យាបាល នឹងបញ្ជូនបុគ្គលិកឱ្យចុះទៅប្រមូលវត្ថុវិភាគយកកាន់មន្ទីរពិសោធន៍នៅក្នុងមជ្ឈមណ្ឌល ។

## ៣-ការបញ្ឈប់ជម្ងឺ

នៅពេលមានអ្នកភូមិរាយការណ៍ពីការងាប់មាន់ និងបក្សីដទៃទៀត ភ្នាក់ងារសុខភាពសត្វភូមិត្រូវចុះទៅពិនិត្យផ្ទះនោះជាបន្ទាន់ ។ នៅពេលភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយរក ឃើញការងាប់ដ៏គួរឱ្យសង្ស័យគាត់ត្រូវៈ

**ក.** ផ្តល់ដំបូន្មានដល់អ្នកភូមិ កុំឱ្យចំអិន ឬបរិភោគមាន់ និងបក្សីដទៃទៀតឈឺ ឬងាប់ ។

**ខ.** ប្រមូលនិងកប់សាកសពដោយប្រើប្រាស់ឧបករណ៍គ្រប់គ្រាន់ (ស្រោមដៃ ស្បែកជើងកវែង និងស្បោងបាស្ទិច) ព្រោះមាន់ និងបក្សីដទៃទៀតដែលមានជម្ងឺផ្ទុក ពេញដោយវីរុស និងអាចឆ្លងរាលដាលទៅបរិស្ថានជុំវិញ មាន់ និងបក្សីដទៃផ្សេងៗទៀត ។

**គ.** ជួយអ្នកភូមិសំអាតបរិវេណក្នុងផ្ទះ និងទីកន្លែងជុំវិញ និងកប់កាកសំណល់ ពោលគឺស្លាប និងលាមក គឺមានពេញទៅដោយវីរុសផងដែរ ។

**ឃ.** បាញ់ថ្នាំសម្លាប់មេរោគក្នុងបរិវេណ លើឧបករណ៍ប្រើប្រាស់ និងទីកន្លែងជុំវិញ ។ ថ្នាំបាញ់សម្លាប់មេេរោគត្រូវលាយជាមួយនឹងទឹកឱ្យបានល្អ វាកាន់តែមានប្រសិទ្ធិភាព ប្រសិនបើបាញ់នៅលើផ្ទៃដែលស្អាត ។

**ង.** លាងសំអាតសំលៀកបំពាក់ សំរាប់ការពារស្បែកជើងកវែង ស្រោមដៃឱ្យបាន ស្អាត និងលាងសំអាតដៃបន្ទាប់ពីបំពេញការងារ ដើម្បីជៀសវាងការឆ្លងរាលដាលរបស់វីរុសទៅលើឧបករណ៍ការពារ ។

**ច.** សូមផ្តល់ព័ត៌មានដល់ អ្នកភូមិឱ្យបានដឹងពីគ្រោះថ្នាក់នៃជម្ងឺញ៉ូកាសចំពោះក្រុមគ្រួសាររបស់គាត់ ។ ជាពិសេសព្យាយាមពន្យល់គាត់ឱ្យយល់ពីគ្រោះថ្នាក់ក្នុងការលក់មាន់ និងបក្សីដទៃទៀត នៅតាមទី

ផ្សារពីព្រោះវានឹងឆ្លងដល់ភូមិផ្សេងៗទៀត។

**ឆ.** ពិនិត្យតាមដានកន្លែងដែលកើតមានជម្ងឺឱ្យបានមួយសប្តាហ៍។ ប្រសិនបើករណីនោះ មានកំរិតគួរសង្ស័យខ្ពស់ ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយត្រូវជូនដំណឹងភ្លាមៗ ដល់ពេទ្យសត្វស្រុក ឬខេត្ត ឬក៏មជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល។ ពួកគាត់នឹងចុះទៅយកវត្ថុវិភាគ។



9



ភ្នាក់ងារសុខភាពសត្វភូមិទូរស័ព្ទជូនដំណឹងទៅពេទ្យសត្វស្រុក

## ខ. ទិដ្ឋភាពភេទនៃផលិតកម្មមាន់តាមភូមិ និងវិធានការការពារជម្ងឺញូកាស

| កិច្ចការ | បុរស | ស្ត្រី | ក្មេងប្រុស | ក្មេងស្រី |
|---|---|---|---|---|
| ការផ្តល់ចំណីដល់មាន់ | | X | X | X |
| ការសាងសង់ទ្រុងមាន់ | X | | | |
| ការចាប់មាន់ | X | | X | |
| តើនរណាត្រូវផ្តល់ការជូនដំណឹងពីតម្រូវការចាប់មាន់ | | X | | |
| ការលក់មាន់ | | X | | |
| ការសំរេចចិត្តនៅពេលលក់មាន់ | X | X? | | |
| ការសំរេចចិត្តក្នុងការធ្វើវ៉ាក់សាំង | X | X | | |
| ការសំរេចចិត្តក្នុងការហូបសាច់មាន់ | X | X | | |
| ហូបសាច់មាន់ | X | X | | |
| ហូបស៊ុត | | | X (កម្រប | X (កម្រប |

ជាទូទៅស្ត្រី តែងតែថែទាំ និងលក់ដូរសត្វតូចដូចជាជ្រូក មាន់ និងទា ដែលការថែទាំសត្វទាំងនេះនៅក្បែរ ផ្ទះ (Gorman 1999) ដូច្នេះហើយ សកម្មភាពផ្សព្វផ្សាយសំរាប់ការអភិវឌ្ឍន៍ការចិញ្ចឹមសត្វជាទ្រង់ ទ្រាយតូច ត្រូវតែផ្អែកលើវិធីសាស្ត្រដែលសំរួលដល់ការចូលរួមរបស់ស្ត្រី។

វាមានសារៈសំខាន់ដែលត្រូវចងចាំថា ការថែទាំបក្សីគឺជាការងារមួយដែលស្ត្រីជាអ្នកទទួលខុសត្រូវ ស្ត្រីភ្ញាក់ពីព្រលឹមចូលដេកយប់ជ្រៅពួកគេទទួលខុសត្រូវក្នុងការស្វែងរកទឹកនិងអុសការរៀបចំម្ហូប អាហារ។ ពួកគេ ជាអ្នកថែរក្សាកូនក្មេងមនុស្សចាស់ និងមនុស្សឈឺ។ ស្ត្រីជាអ្នកថែរក្សាផ្ទះធ្វើការនៅតាមវាល និងថែទាំកូនចៅ។ សកម្មភាពផ្សព្វផ្សាយត្រូវតែសំរបសំរួលភាពមមាញឹករបស់ស្ត្រីនៅតាមជនបទ(Alders 1996)។

## សង្ខេប

បអប នេះ ត្រូវបានរៀបរៀងឡើង ដើម្បីជាឯកសារគ្រប់គ្រាន់សំរាប់ភ្នាក់ងារសុុខភាពសត្វភូមិ និងអ្នកផ្សព្វផ្សាយក្នុងប្រទេសកម្ពុជាឱ្យយល់ដឹងពីជម្ងឺញ៉ូកាស។

- ញ៉ូកាសជាជម្ងឺឆ្លងដែលបង្កដោយវីរុស និងឆ្លងរាលដាលយ៉ាងឆាប់រហ័ស។ ជម្ងឺនេះបង្កឱ្យមាន់និងបក្សីដទៃទៀតងាប់ជាច្រើនក្បាល។ វាជាជម្ងឺបង្កគ្រោះមហន្តរាយ។ ប្រសិនបើមាន់ និងបក្សីដទៃទៀត របស់អ្នកបានប៉ះពាល់ជាមួយសត្វមាន់ និងបក្សីដទៃទៀតឈឺ ពួកវានឹងចាប់ផ្តើមឈឺ ២-៣ថ្ងៃបន្ទាប់។ អង់ទីប៊ីយ៉ូទិចគ្មានប្រសិទ្ធិភាពក្នុងការព្យាបាលជម្ងឺនេះ។ បអប នេះបង្ហាញពីរោគសញ្ញាផងដែរ។ របៀបចម្លងជាចំបងនៃជម្ងឺញ៉ូកាស គឺការចិញ្ចឹមមាន់ និងបក្សីដទៃទៀតលែងឱ្យស៊ីដោយសេរី និងការបំលាស់ទីសត្វមាន់ និងបក្សីដទៃទៀតពីកន្លែងមួយទៅកន្លែងមួយទៀត។
- ការត្រួតពិនិត្យជម្ងឺមានន័យថា ជាសកម្មភាពមួយដែលមានបំណងការពារទប់ ស្កាត់ដើម្បីកាត់បន្ថយជម្ងឺ ឬធ្វើឱ្យជាសះស្បើយឡើងវិញ។ តួនាទីរបស់ភ្នាក់ងារសុខភាពភូមិ ក្នុងការត្រួតពិនិត្យជម្ងឺ ញ៉ូកាសមាន:

  + ចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំង

  + ការអង្កេតឃ្លាំមើល និងការត្រួតពិនិត្យ

  + ការផ្តល់ព័តិមាន និងការបញ្ចុះបញ្ចូល

  + ការធ្វើរបាយការណ៍

- ដើម្បីត្រួតពិនិត្យ និងការពារទប់ស្កាត់ជម្ងឺញ៉ូកាសនៅតាមភូមិ ភ្នាក់ងារសុខភាពសត្វភូមិមានភារកិច្ចចំបង ៥ដែលត្រូវធ្វើគឺ:

១- ចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំង

២- អង្កេត (ឃ្លាំមើល)

៣- ត្រួតពិនិត្យ និងធ្វើរបាយការណ៍

៤- បញ្ឈប់ជម្ងឺ

៥- ផ្តល់ដំណឹង និងបញ្ចុះបញ្ចូល

ដើម្បីទទួលបានជោគជ័យ ក្នុងការប្រយុទ្ធនឹងជម្ងឺញ៉ូកាស អ្នកភូមិមានតួនាទី យ៉ាងសំខាន់ដូចជា:

១. អ្នកភូមិត្រូវរាយការណ៍ប្រាប់ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយប្រសិនបើមានមាន់ និងបក្សីដទៃទៀតងាប់។

២. អ្នកភូមិត្រូវការពារដៃរបស់ខ្លួនដោយពាក់ស្រោមដៃ ឬថង់ប្លាស្ទិចដើម្បីចាប់កាន់សាកសព ឬមាន់ និង បក្សីដទៃទៀតមានជម្ងឺ។ វិធីល្អបំផុត គឺស្នើសុំជំនួយពីភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយ។

៣. អ្នកភូមិមិនត្រូវបរិភោគមាន់ និងបក្សីដទៃទៀតឈឺ ឬងាប់។

៤. អ្នកភូមិត្រូវកប់ ឬដុតរៀងរាល់ពេលមានមាន់ និងបក្សីដទៃទៀតងាប់។

៥. អ្នកភូមិត្រូវបោសសំអាតទីធ្លាជុំវិញរៀងរាល់ថ្ងៃ។

៦. អ្នកភូមិមិនត្រូវចិញ្ចឹមមាន់ និងបក្សីដទៃទៀតក្រោមផ្ទះ សង់ទ្រុងមាន់ និងបក្សីដទៃទៀតឱ្យ ឆ្ងាយពីផ្ទះ។

៧. អ្នកភូមិមិនត្រូវចិញ្ចឹមមាន់ និងបក្សីដទៃទៀតនៅតាមវាល តាមបឹង អូរ ឬស្ទឹង ត្រូវធ្វើរបងខណ្ឌឱ្យបានត្រឹមត្រូវ។

៨. អ្នកភូមិមិនត្រូវចិញ្ចឹមមាន់និងបក្សីដទៃទៀតជាមួយគ្នា។

៩. នៅពេលមានមាន់ និងបក្សីដទៃទៀតងាប់ អ្នកភូមិត្រូវរាយការណ៍មកភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វ ផ្សាយ។

១០. មុនពេលដាក់មាន់ និងបក្សីថ្មីចូលចិញ្ចឹម អ្នកភូមិត្រូវទុកវាដាច់ដោយឡែកពី មាន់ និងបក្សីចាស់ យ៉ាងហោច១៤ថ្ងៃ។

១១. អ្នកភូមិត្រូវលាងដៃនឹងសាប៊ូ ឬផេះមុន និងក្រោយប៉ះពាល់ជាមួយមាន់ និង បក្សីដទៃទៀត។

១២. អ្នកភូមិត្រូវលាងសំអាតរំងាប់មេរោគលើសម្ភារៈប្រើប្រាស់ ក្រោយពីបញ្ចប់ការងារ។

**<u>ត្រូវចងចាំជានិច្ច</u>**

**<u>រាយការណ៍ពីមាន់ និងបក្សីដទៃទៀតឈឺ!</u>** ប្រសិនបើមាន់ និងបក្សីដទៃទៀត បង្ហាញពីជម្ងឺញ៉ូកាស ឬបានប៉ះពាល់ជាមួយមាន់ និងបក្សីដទៃទៀតឈឺ។ អ្នកត្រូវផ្តល់ព័ត៌មានដល់ពេទ្យសត្វស្រុក ឬខេត្ត ឬទាក់ទងមកកាន់ទូរស័ព្ទលេខ: **០១២ ២១ ៤៩ ៧០ / ០១២ ៨៣ ៣៧ ៩៥**

## ច. ជម្ងឺផ្តាសាយបក្សី

**- ផ្តាសាយបក្សី** ជាជម្ងឺថ្មីមួយដែលជាជម្ងឺបង្កគ្រោះថ្នាក់ ពីព្រោះវាឆ្លងដល់សត្វ និងមនុស្ស។

**- ផ្តាសាយបក្សី** ជាជម្ងឺបង្កបញ្ហាយ៉ាងធ្ងន់ធ្ងរដល់អ្នកចិញ្ចឹមមាន់ និងបក្សីដ៏ទៃទៀត ធ្វើឱ្យពួកគេបាត់បង់ប្រាក់កាសបណ្តាលមកពីមាន់និងសត្វបក្សីដ៏ទៃទៀតងាប់និងការសំលាប់ដែលត្រូវបានធ្វើឡើងដើម្បីទប់ស្កាត់ការរីករាលដាលជម្ងឺនេះ ដូចជម្ងឺញ៉ូកាសដែរ។

-រោគសញ្ញារបស់ **ជម្ងឺផ្តាសាយបក្សី** មានលក្ខណៈដូចនឹងជម្ងឺញ៉ូកាសដែរ ប៉ុន្តែផ្តាសាយបក្សីឆ្លងទៅមនុស្សចំពោះជម្ងឺញ៉ូកាសវិញ អាចធ្វើឱ្យមនុស្សឈឺភ្នែកក្រហម។

**មានតែលទ្ធផលមន្ទីរពិសោធន៍ទេ ដែលបញ្ជាក់ច្បាស់ថា វាជាជម្ងឺផ្តាសាយបក្សី ឬក៏មិនមែន។**

### តើអ្វីទៅជាជម្ងឺផ្តាសាយបក្សី?

ផ្តាសាយបក្សីជាជម្ងឺឆ្លងដែលបង្កដោយវីរុស និងឆ្លងរាលដាលយ៉ាងឆាប់រហ័ស។ ជម្ងឺនេះបង្កឱ្យមាន់ និង បក្សីដ៏ទៃទៀតងាប់ច្រើន និងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់មនុស្សទៀតផង។



**<u>វីរុសជម្ងឺផ្តាសាយបក្សី</u>**

❋ ផ្តាសាយបក្សីជាជម្ងឺថ្មីមួយ ដែលបានកើតក្នុងព្រះរាជាណាចក្រកម្ពុជា នឹងត្រូវបានប្រកាសលើកដំបូងជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅថ្ងៃទី ២៣ ខែមករា ឆ្នាំ២០០៤។

## ១. រោគសញ្ញាចំពោះបក្សី

### ក- មាន់

ជាញឹកញាប់បំផុតមាន់ងាប់យ៉ាងឆាប់រហ័ស ដែលធ្វើឱ្យអ្នកមិនអាចសង្កេតពីរោគសញ្ញារបស់វាបាន ប៉ុន្តែជួនកាល អ្នកនឹងសង្កេតឃើញពីរោគសញ្ញារបស់វាផងដែរដូចជា:

- មាន់ដកដង្ហើមញាប់ មាត់ចំហ កឡើងត្រង់
- សិរណង់ឡើងពណ៌ស្វាយ និងហើម
- រាគរូសយ៉ាងខ្លាំង ហើយជាញឹកញាប់លាមកវាឡើងពណ៌បៃតង ។



មាន់ដកដង្ហើមញាប់ មាត់ចំហ កឡើងត្រង់



សិរ ណង់ឡើងពណ៌ស្វាយ និងហើម

### ខ- ទា

រោគសញ្ញាចំពោះសត្វទាមាន:

- សត្វឈឺ អង្គុយ ឬឈរ ដោយមានសភាពពាក់កណ្តាលសន្លប់ (ងងុយដេក)
- ក្បាលសំយ៉ុងចុះទៅដី រយៈពេល ២ ទៅ ៤ ម៉ោង ហើយងាប់
- ភ្នែកពណ៌ស
- រាគពណ៌ស ។



សត្វឈឺអង្គុយ ឬឈរដោយមានសភាពពាក់កណ្តាលសន្លប់ (ងងុយដេក)



ក្បាលសំយ៉ុងចុះទៅដី



ភ្នែកពណ៌ស



ភាគពណ៌ស

ផ្តាសាយបក្សីនិងជម្ងឺញ៉ូកាសមានវិធានការការពារនិងទប់ស្កាត់ប្រហាក់ប្រហែលគ្នាដែលបានរៀបរាប់ដូចខាងលើ ។

ភ្នាក់ងារសុខភាពសត្វភូមិ និងភ្នាក់ងារផ្សព្វផ្សាយ ត្រូវអនុវត្តវិធានការណ៍ទាំងអស់ដែលបានរៀបរាប់ខាងលើពីជម្ងឺញ៉ូកាស ។

ផ្តាសាយបក្សី ពុំទាន់មានគោលនយោបាយធ្វើយុទ្ធនាការចាក់វ៉ាក់សាំងទេក្នុងប្រទេសកម្ពុជាប៉ុន្តែវ៉ាក់សាំងប្រឆាំងជម្ងឺ ញ៉ូកាសត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ។

**ឯកសារយោង**

1- Robyn Alders and Peter Spradbrow (2000). In: Newcatle Disease in Village Chickens, A Field Manual, 1-29 pages
2- UNDP/OPS/CARERE and FAO (1999). In: “Workshop on Extension Programs for Control of Newcatle Disease in Village Chickens”, 1-53 pages
3- FAO/DAHP (2000). Guide for Village Animal Health Workers on Surveillance and Control of Avain Influenza in Cambodia, 2-26 pages
4- Gorman, S. (1999) Gender and Development in Cambodia: An Overview. Cambodia Development Resource Institute, Phnom Penh, Working Paper No. 10.
5- Alders, R. (1996) Facilitating women’s participation in village poultry projects: Congress, New Delhi, India, Vol. III, pp. 441-447

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ២០០ វិថីព្រះនរោត្តម ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: ០១២ ៨៣៣ ៧៧៧ ឬ ០១២ ៨២៦ ៦១៧

ទូរសារ: ៨៥៥ ២៣ ២១០ ៩៤៨ ឬ ៨៥៥ ២៣ ២១៣ ០១១

អ៊ីម៉ែល: kunso@camnet.com.kh b ឬ mak_soeun@camnet.com.kh